**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ**
**និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**

# សារណាបញ្ចប់ការសិក្សា

## សេវាប្រាក់បញ្ញើ-សន្សំ

កម្មសិក្សាពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ ដល់ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១

ឈ្មោះស្ថាប័ន៖ **ធនាគារ កាណាឌីយ៉ា ក.អ ការិយាល័យកណ្តាល(Canadia Bank Plc.)**

| | |
|---|---|
| តាក់តែងឡើងដោយ | សាស្ត្រាចារ្យណែនាំ |
| និស្សិតឈ្មោះ **ស៊ិត គន្ធា** | លោកស្រីសាស្ត្រាចារ្យ **ឡុង ម៉ាទីឌី** |
| ថ្នាក់បរិញ្ញាបត្រ ធនាគារ និង ហិរញ្ញវត្ថុ | ឆ្នាំសិក្សា ២០១៧ |
| ជំនាន់ទី១៤ | ឆ្នាំសរសេរបាយការណ៍ ២០២១ |

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ **ស៊ិត គន្ធា** ជានិស្សិតថ្នាក់បរិញ្ញាបត្រ ធនាគារ និង ហិរញ្ញវត្ថុ ឆ្នាំទី៤ ជំនាន់ទី១៤ នៃ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្រុម B4C3 ឆ្នាំសិក្សា ២០២០-២០២១។

**យើងខ្ញុំសូមថ្លែងអំណរគុណ និងសូមសម្តែងនូវការគោរពយ៉ាងខ្ពង់ខ្ពស់ និងកតញ្ញូតាធម៌ដ៏ជ្រាលជ្រៅចំពោះ**

លោកអ្នកមានគុណទាំងពីរ ដែលបានផ្តល់កំណើតចិញ្ចឹមបីបាច់ថែរក្សា អប់រំទូន្មាន ប្រៀនប្រដៅតាំងតែពីតូចរហូតមកដល់សព្វថ្ងៃ និងព្យាយាមលើកទឹកចិត្តដល់យើងខ្ញុំ ទាំងការរស់នៅប្រចាំថ្ងៃក៏ដូចជាការសិក្សាផងដែរ ហើយថែមទាំងបានបណ្តុះគោលគំនិត យើងខ្ញុំក្នុងការរស់នៅប្រកបដោយសីលធម៌ និងជាពលរដ្ឋល្អដើម្បីតបស្នងដល់សង្គមជាតិ។ បន្ថែមលើសពីនេះទៅទៀត យើងខ្ញុំសូមថ្លែងអំណរគុណសមាជិកក្នុងក្រុមគ្រួសារ ដែលតែងតែជួយទូន្មាន និងដាស់តឿនបន្ថែមទៀត ឲ្យខិតខំសិក្សារៀនសូត្ររហូតទទួលបាននូវសមិទ្ធផលមួយនេះ។

លោកឯកឧត្តម បណ្ឌិត **លុយ ចណ្ណា** សាកលវិទ្យាធិកា សាកលវិទ្យាធិការង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង សាស្ត្រាចារ្យដែលបានសហការគ្នាបង្កើតកម្មវិធីសិក្សានេះឡើង ហើយលោកព្យាយាមរិះរកគំនិត បទពិសោធន៍ និងវិធីសាស្ត្រផ្សេងៗទៀតដើម្បីចែករំលែក បង្ហាត់បង្រៀន និងជួយកែលំអរាល់ចំណុចខ្វះខាត់របស់យើងខ្ញុំ។

ជាពិសេសខ្ញុំសូមថ្លែងអំណរគុណដល់ លោកស្រី សាស្ត្រាចារ្យ **ឡុង ម៉ាមីឌី** ដែលបានចំណាយពេលវេលាដ៏មានតម្លៃ ក្នុងការចែករំលែកនូវបទពិសោធន៍ ចំណេះដឹង និងបានដឹកនាំយើងខ្ញុំ ដើម្បីធ្វើការស្រាវជ្រាវ និងបានសម្រេចនូវគម្រោងបញ្ចប់ការសិក្សាជាស្ថាពរ ដោយមិនគិតពីការនឿយហត់ និងភាពមមាញឹករបស់លោកគ្រូផ្ទាល់។ អ្វីដែលពិសេសទៅទៀតនោះ គឺលោកគ្រូតែងតែផ្តល់នូវមតិរិះគន់ ដើម្បីស្ថាបនា កែសម្រួល ផ្តល់ជាឯកសារដែលពាក់ព័ន្ធក្នុងការស្រាវជ្រាវ និងបានជម្រុញលើកទឹកចិត្តយើងខ្ញុំ តាំងពីចាប់ផ្តើមរហូតដល់បញ្ចប់ការងារបានជោគជ័យដោយក្តីសោមនស្សរីករាយ។

ជាចុងក្រោយនេះយើងខ្ញុំសូមធ្វើការគោរពដឹងគុណ និងគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះមាតាបិតា លោកឯកឧត្តមសាកលវិទ្យាធិកា សាកលវិទ្យាធិការង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង សាស្ត្រាចារ្យ មិត្តនិស្សិតរួមជំនាន់ និងសិស្សច្បងជំនាន់មុនដែលបានចែករំលែកបទពិសោធន៍ និងគំនិតល្អៗ ឲ្យជួបប្រទះនូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លាតឃ្លាឡើយ។

# **អារម្ភកថា**

វិស័យធនាគារពាណិជ្ជ គឺជាវិស័យមួយក្នុងចំណោមវិស័យហិរញ្ញវត្ថុនានា ដែលមានសក្តានុពលទូទាំងពិភពលោកដែលអាចបង្កើតប្រាក់ចំណូលបានយ៉ាងច្រើន។ នាទស្សវត្សចុងក្រោយនេះ មានការរីកចម្រើនទៅលើការប្រកួតប្រជែងទីផ្សារហិរញ្ញវត្ថុ បច្ចេកវិទ្យាសេវាលឿនរហ័ស ព្រមទាំងកាត់បន្ថយចំណាយ និងមានសុវត្ថិភាពខ្ពស់បំផុត។ ទាំងនេះគឺជាសញ្ញាណវិជ្ជមានមួយ សម្រាប់អ្នកប្រើប្រាស់សេវាធនាគារ។ វិស័យធនាគារទាំងធនាគារក្នុងស្រុក និងធនាគារវិនិយោគមកពីប្រទេសក្រៅ បានខិតខំពង្រីកតំបន់ប្រតិបត្តិការរបស់ខ្លួនស្ទើរគ្រប់ ២៥ខេត្តក្រុង រួមទាំងបណ្តារស្រុកមួយចំនួន ដែលធ្វើឲ្យសេវាមួយនេះមានការរីកចម្រើនយ៉ាងខ្លាំង និងមានភាពងាយស្រួលដល់អ្នកទទួលសេវា។

តែទោះបីជាទីផ្សារហិរញ្ញវត្ថុបានឈរជើងរីកចម្រើនជាច្រើនឆ្នាំមកក៏ដោយ ធនាគារជាតិនៃកម្ពុជាបានព្យាករការទទួលបានប្រាក់ចំណេញពីវិស័យហិរញ្ញវត្ថុ និងមានការធ្លាក់ចុះ ដោយសារការរីករាលដាលនៃជំងឺកូវីដ ១៩ ដែលបង្កផលប៉ះពាល់ដល់សេដ្ឋកិច្ចពិភពលោកស្ទើរគ្រប់វិស័យ បូករួមទាំងប្រទេសកម្ពុជា។

ដោយមើលឃើញពីភាពរីកចម្រើនរបស់ធនាគារកាណាឌីយ៉ា ក.អ ចាប់តាំងពីឆ្នាំ ១៩៩១ និងភាពរឹងមាំដែលបានឈរជើងយ៉ាងល្អប្រសើរនៅក្នុងកំឡុងពេលនៃការរីករាលដាលជំងឺកូវីដ ១៩ សម្រាប់គ្រប់សេវាប្រតិបត្តិការទាំងអស់ ហើយអតិថិជននៅតែបន្តសេចក្តីទុកចិត្ត និងគាំទ្រមកលើការបម្រើសេវារបស់ធនាគាររហូតមកដល់ពេលបច្ចុប្បន្ន។ លក្ខណៈពិសេសនៃសេវាហិរញ្ញវត្ថុរបស់ធនគារកាណាឌីយ៉ា ក.អ ដោយសារធនាគារមានសេវាយ៉ាងច្រើនប្រភេទផ្តល់ជូនអតិថិជនរួមមាន៖ សេវាឥណទាន សេវាប្រាក់បញ្ញើ-សន្សំ សេវាផ្ទេរប្រាក់ទាំងក្នុងនិងក្រៅប្រទេស សេវាទូរទាត់សាច់ប្រាក់ សេវាដកឬដាក់ប្រាក់ និងសេវាកម្មផ្សេងៗជាច្រើនទៀត។ ចំពោះចំណុចនេះបានធ្វើឲ្យយើងខ្ញុំមានការចាប់អារម្មណ៍យ៉ាងខ្លាំង ដោយបានសម្រេចចិត្តធ្វើការសិក្សាស្រាវជ្រាវទៅលើវិស័យហិរញ្ញវត្ថុ និងលើកយកទ្រឹស្តីពាក់ព័ន្ធផ្សេងៗ ដែលជាផ្នែកមួយសំខាន់នៃភាពជោគជ័យរបស់ធនាគារ។ ទន្ទឹម និងការស្រាវជ្រាវយើងខ្ញុំនិងលើកយកការស្រាវជ្រាវដោយផ្តោតចម្បងលើ សេវាកម្មប្រាក់បញ្ញើ-សន្សំដែលជាសេវាដ៏ចាំបាច់បំផុតដើម្បីជួយឲ្យធនាគារឈរជើង រឹងមាំបានរហូតមកដល់ពេលបច្ចុប្បន្ននេះ ពាក់ព័ន្ធនិងយុទ្ធសាស្ត្រទីផ្សារ គុណសម្បត្តិ និងផលចំណេញដែលអតិថិជន និងធនាគារទទួលបានពីសេវាមួយនេះ ព្រមទាំងបានរៀបចំចងក្រងការសិក្សាក្រោមប្រធានបទ (**សេវាប្រាក់បញ្ញើ-សន្សំ**) នេះឡើង។

ជាចុងបញ្ចប់នៃការសរសេររបាយការណ៍នេះ ពិតជាមាននូវកំហុសខុសឆ្គងទៅលើខ្លឹមសាររូបភាពអក្ខរាវិរុទ្ធ ដោយអចេតនាជាក់ជាមិនខាន ហេតុដូចនេះហើយយើងខ្ញុំនឹងទទួលយកនូវការរិះគន់ កែលំអរ ក្នុងន័យស្ថានាទាំងឡាយ ដែលបានកើតមានឡើងអចេតនា ពីសំណាក់លោកសាស្ត្រាចារ្យ មិត្តអ្នកអាន និងសាធារណៈជន ពីគ្រប់មជ្ឈដ្ឋាន ដោយសេចក្តីគោរពខ្ពង់ខ្ពស់ ក្នុងគោលបំណងឲ្យស្នាដៃនេះកាន់តែមានអត្ថ

ប្រយោជន៍ក្នុងការយកទៅសិក្សាស្រាវជ្រាវបន្ត។ យើងខ្ញុំសូមជូនពរលោកសាស្ត្រាចារ្យ មិត្តអ្នកអាន និងសាធារណៈជនទាំងអស់មានសុខភាពល្អ ទទួលបានជោគជ័យប្រាថ្នាអ្វីឲ្យសម្រេចបានដូចបំណង។

# មាតិកា

ទំព័រ


បញ្ជីអក្សរកាត់ ........ v

បញ្ជីតារាង ........ vi

បញ្ជីរូបភាព ........ vii

បញ្ជីឧបសម្ព័ន្ធ ........ viii


## សេចក្តីផ្តើម


១. លំនាំបញ្ហាការស្រាវជ្រាវ ........ ១

២. ចំណោទបញ្ហានៃការស្រាវជ្រាវ ........ ២

៣. គោលបំណងនៃការស្រាវជ្រាវ ........ ៣

៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ ........ ៣

៥. វីធីសាស្ត្រនៃការស្រាវជ្រាវ ........ ៣

៥.១ ប្រភេទនៃការស្រាយជ្រាវ ........ ៣

៥.២. ប្រភេទនៃទិន្នន័យ ........ ៤

៥.៣. វិធីសាស្ត្រវិភាគទិន្នន័យ ........ ៤

៦. សារៈសំខាន់នៃការស្រាវជ្រាវ ........ ៥

៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ ៦


## ជំពូកទី១

## រំលឹកទ្រឹស្តី


១.១. ស្ថានភាពទូទៅរបស់ធនាគារពាណិជ្ជ ........ ៧

១.១.១. ប្រវត្តិនៃការកកើតធនាគារ ........ ៧

១.១.២. និយមន័យធនាគារពាណិជ្ជ ........ ៧

១.២. លក្ខណៈទូទៅនៃសេវាប្រាក់បញ្ញើ-សន្សំ ........ ៧

១.២.១. និយមន័យ ........ ៧

១.២.២. ប្រភេទនៃប្រាក់បញ្ញើ-សន្សំ ........ ៨

១.៣. គោលបំណង និងមុខងារនៃប្រាក់បញ្ញើ-សន្សំ ........ ៨
១.៤. គុណសម្បត្តិ និងគុណវិបត្តិនៃប្រាក់បញ្ញើ-សន្សំ ........ ៩
១.៤.១. ប្រាក់បញ្ញើ-សន្សំសំច័យ ........ ៩
១.៤.២. ប្រាក់បញ្ញើ-សន្សំមានកាលកំណត់ ........ ១០
១.៥. ហានិភ័យនៃការប្រើប្រាស់សេវាប្រាក់បញ្ញើ-សន្សំ ........ ១១
១.៦. ប្រភេទការប្រាក់ ........ ១១
១.៦.១. ការប្រាក់ទោល (Simple Interest) ........ ១១

## ជំពូកទី ២

### ស្ថានភាពទូទៅរបស់ធនាគារ

២.១. ប្រវត្តិសង្ខេបរបស់ធនាគារកាណាឌីយ៉ា ក.អ ........ ១៣
២.២ ទស្សនៈវិស័យ បេសកម្ម គោលដៅនិងពាក្យស្លោករបស់ធនាគារកាណាឌីយ៉ាក.អ........ ១៣
២.២.១. ទស្សនៈវិស័យ ........ ១៣
២.២.២. បេសកម្ម ........ ១៣
២.២.៣. គោលដៅ ........ ១៤
២.២.៤. ពាក្យស្លោក ........ ១៤
២.៣. ស្លាកសញ្ញា និងអត្ថន័យនៃស្លាកសញ្ញា ........ ១៤
២.៣.១. ស្លាកសញ្ញា ........ ១៤
២.៣.២. អត្ថន័យនៃស្លាកសញ្ញា ........ ១៤
២.៤. ថ្នាក់ដឹកនាំក្រុមហ៊ុន ........ ១៤
២.៥. បណ្តាញប្រតិបត្តិការរបស់ធនាគារ កាណាឌីយ៉ា ក.អ ........ ១៥
២.៦. ទីតាំងរបស់ធនាគារកាណាឌីយ៉ា ........ ១៥
២.៧. បណ្តាសាខានៃធនាគារកាណាឌីយ៉ា ក.អ ........ ១៦
២.៨. ផលិតផល និងសេវាកម្មរបស់ធនាគារកាណាឌីយ៉ា ក.អ ........ ១៦

# ជំពូកទី៣
# ប្រាក់បញ្ញើ-សន្សំរបស់ ធនាគារ ភាគលាឌីយ៉ា ក.អ ទីស្នាក់ការកណ្តាល


៣.១ ផលិតផលប្រាក់បញ្ញើ ........ ១៨

៣.១.១. គណនីសំចៃ(Saving Account) ........ ១៨

៣.១.២. គណនីចរន្ត (Current Account) ........ ២១

៣.១.៣. គណនីមានកាលកំណត់ (Fixed Deposit Account) ........ ២២

៣.១.៤. គណនីមានអនឡាញ (Online Account) ........ ២២

៣.១.៥. គណនីវរជន (Elite Account) ........ ២៨

៣.១.៦. គណនីកុមារ (Junior Account) ........ ៣០

៣.១.៧. គណនីសន្សំសម្រាប់អាពាហ៍ពិពាហ៍ (Wedding Saving Account) ........ ៣២

៣.១.៨. គណនីបញ្ញើតាមផែនការ (Installment Deposit Account) ........ ៣៤

៣.២. យុទ្ធសាស្រ្តចែកចាយ ........ ៣៧

៣.២.១. ការជ្រើសរើសទីតាំងការិយាល័យ ទីស្នាក់ការកណ្តាល ........ ៣៧

៣.២.២. ការបែងចែកផលិតផលសេវាកម្ម ........ ៣៧

៣.៣ យុទ្ធសាស្រ្តជំរុញលក់ ........ ៣៨

៣.៣.១.ការផ្សព្វផ្សាយតាមប្រព័ន្ធ Media ........ ៣៨

៣.៣.២. ការផ្សព្វផ្សាយជាសាធារណៈ ........ ៣៨

៣.៣.៣. ការផ្សព្វផ្សាយដោយផ្ទាល់ ........ ៣៨

៣.៣.៤. ការផ្សព្វផ្សាយតាមប្រព័ន្ធអេឡិចត្រូនិច ........ ៣៩

៣.៤ យុទ្ធសាស្រ្តលើកត្តាមនុស្សសាស្រ្ត ........ ៣៩

៣.៥. យុទ្ធសាស្រ្តលើកត្តារូបសាស្រ្ត ........ ៤០

៣.៦. យុទ្ធសាស្រ្តផលិតភាព និងគុណភាព ........ ៤២

## ជំពូកទី៤

## ការវិភាគSWOT

៤.១. ចំណុចខ្លាំង........................................................................................................៤៣

៤.២. ចំណុចខ្សោយ ........................................................................................................ ៤៤

៤.៣. ឱកាស ........................................................................................................ ៤៤

៤.៤ ការគំរាមគំហែង ........................................................................................................ ៤៤

## សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

១. សេចក្តីសន្និដ្ឋាន ........................................................................................................ ៤៥

២. ការផ្តល់អនុសាសន៍ ........................................................................................................ ៤៥

# បញ្ជីអក្សរកាត់

CNB : Canadia Bank
ATM : Automatic Teller Machine
SWIFT : Society for Worldwide Interbank Financial Telecommunication
USD : United State Dollar
LC : Letter of Credit
PLC : Public Limited Company

# បញ្ជីតារាង

តារាងទី១ ៖ បញ្ជីអត្រាការប្រាក់គណនីសំច័យ

តារាងទី២ ៖ បញ្ជីអត្រាការប្រាក់គណនីបញ្ញើមានការកំណត់

តារាងទី៣ ៖ បញ្ជីអត្រាការប្រាក់គណនីអនឡាញ

តារាងទី៤ ៖ បញ្ជីអត្រាការប្រាក់គណនីកុមារ

តារាងទី៥ ៖ បញ្ជីអត្រាការប្រាក់គណនីអាពាហ៍ពិពាហ៍

តារាងទី៦ ៖ បញ្ជីអត្រាការប្រាក់គណនីបញ្ញើតាមផែនការ

# បញ្ជីរូបភាព

រូបភាពទី១ ៖ ស្លាកសញ្ញារបស់ធនាគារ កាណាឌីយ៉ា ក.អ

រូបភាពទី២ ៖ ការិយាល័យកណ្តាលរបស់ធនាគារ កាណាឌីយ៉ា ក.អ

រូបភាពទី៣ ៖ SWIFT

រូបភាពទី៤ ៖ ស្លាកសញ្ញាកាតអាចប្រើជាមួយម៉ាសីន អេ ធី អឹម របស់ធនាគារ កាណាឌីយ៉ា ក.អ

រូបភាពទី៥ ៖ ស្លាកសញ្ញាដៃគូអាជីវកម្មរបស់ធនាគារ កាណាឌីយ៉ា ក.អ

រូបភាពទី៦ ៖ កាតរបស់ធនាគារ កាណាឌីយ៉ា ក.អ

# បញ្ជីឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទី១៖ កម្រងសំណួរស្រាវជ្រាវស្តីអំពី“ប្រាក់បញ្ញើ សន្សំរបស់របស់ធនាគារ កាណាឌីយ៉ា កអ ទីស្នាក់ការកណ្តាល”

ឧបសម្ព័ន្ធទី២៖ កម្រងសំណួរស្រាវជ្រាវ

# សេចក្តីផ្តើម

## ១. លំនាំបញ្ហាការស្រាវជ្រាវ

រហូតមកដល់ពេលបច្ចុប្បន្ននេះ សកម្មភាពនៃការប្រកួតប្រជែងផ្នែកពាណិជ្ជកម្មកំពុងមានការរីកចំរើនខ្លាំងស្របពេលដែលមានបច្ចេកវិទ្យា និងយុទ្ធសាស្ត្រនៃការគ្រប់គ្រងរបស់ក្រុមហ៊ុនធំៗកំពុងតែមានការផ្លាស់ប្តូរយ៉ាងឆាប់រហ័ស ស្របពេលបំរែបំរួលសង្គមពីមួយថ្ងៃទៅមួយថ្ងៃ។ប្រទេសកម្ពុជាមានកំណើនសេដ្ឋកិច្ចកើនឡើងនៅកំឡុង ១០ឆ្នាំចុងក្រោយនេះ បើយើងក្រលេកមើល GDP នៅក្នុងប្រទេសកម្ពុជាចន្លោះឆ្នាំ ២០១០ ដល់ឆ្នាំ ២០១៩ មានការកើនឡើងជារៀងរាល់ឆ្នាំចន្លោះពី ៨.៩% ក្នុងមួយឆ្នាំដល់ ១៤.១២% ។ដោយឡែកនៅឆ្នាំ ២០២០ ប្រទេសកម្ពុជាទទួលរងវីរុសកូវីត១៩ ទើប GDP ធ្លាក់ចុះ ២.៩០%[1]។ បើគិតមកត្រឹមខែ កក្កដា ឆ្នាំ ២០២០ ធនាគារពាណិជ្ជនៅប្រទេសកម្ពុជាមានចំនួន ៥១ធនាគារ ក្នុងនោះមានធនាគារដែលមានសក្តានុពលចំនួន ១០ធនាគារ រួមមាន៖ ធនាគារអេស៊ីលីដា(ACLEDA Bank) ធនាគារពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជា (FTB Bank) ធនាគារសហពាណិជ្ជ(UCB Bank) ធនាគារ ជេត្រាស់(J Trust Royal Bank) ធនាគារវឌ្ឍនៈ (Vattanac Bank) ធនាគារកម្ពុជាសាធារណៈ(Kampu Bank) ធនាគារ មេយប៊ែង(Maybank Cambodia) ធនាគារBank Of China Phnom Penh ធនាគារ ABA ក្នុងចំណោមធនាគារទាំងនេះក៏មានធនាគារកាណាឌីយ៉ា (Canadia Bank)មួយផងដែរ[2]។ធនាគារកាណាឌីយ៉ា ក.អ បានប្រែក្លាយខ្លួនតាំងពីធនាគារឯកទេសរហូតបានក្លាយជាធនាគារពាណិជ្ជក្នុងគោលបំណងស្វែងរកប្រាក់ចំណូលដោយខ្លួនឯង ក្រោមការផ្តល់សេវាយ៉ាងច្រើនជូនដល់អតិថិជន ក្នុងនោះសេវាប្រាក់បញ្ញើ-សន្សំដែលដើរតួយ៉ាងសំខាន់។ សេវានេះមិនត្រឹមតែកាត់បន្ថយប្រាក់ចំណាយអោយធនាគារប៉ុណ្ណោះទេ វាបានជួយជាប្រភពទុនដែលទទួលបានយកទៅបង្វិលទៅតែណទានផ្សេងៗ ក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ។

រហូតដល់ពេលនេះធនាគារកាណាឌីយ៉ា ក.អ ក៏បានពង្រីកខ្លួន និងបង្កើតសាខាគ្រប់ខេត្តក្រុងទូទាំងប្រទេសកម្ពុជា ដែលធ្វើអោយមានការកាត់ចំណែកទីផ្សារហិរញ្ញវត្ថុមានតាំងពីទីប្រជុំជន រហូតដល់ចុងកាត់មាត់ញកថែមទៀតផងដែរ មិនតែប៉ុណ្ណោះធនាគារកាណឌីយ៉ាបានទទួលពានរង្វាន់ជាច្រើនបន្តបន្ទាប់ក្នុងកំឡុងពេលប៉ុន្មានឆ្នាំជាប់គ្នា បើគិតត្រឹមឆ្នាំ២០២០ មកដល់ឆ្នាំ២០២១ ធនាគារបានទទួលពាន់រង្វាន់ដូចជា៖ នៅខែមិថុនាឆ្នាំ២០២០ បានឈ្នះពានរង្វាន់ ៣ជាប់ៗគ្នា បន្ថែមពីលើពានរង្វាន់ "The Best SME Bank Cambodia

[1]ដកស្រង់ចេញពីគេហទំព័រhttps://knoema.com/atlas/Cambodia/GDP?mode=amp , Cambodia GDP 2010-2019

[2]ដកស្រង់ពីគេហទំព័រ
https://en.m.wikipedia.org/wiki/List_of_banks_in_Cambodia

2020″ រួមមាន ពានរង្វាន់"Best Retail Bank In Cambodia 2020" ពានរង្វាន់"The Asian Banker" និង ពានរង្វាន់ "ធនាគារក្នុងស្រុកឆ្នើម" និង "ធនាគារទទួលខុសត្រូវសង្គមខ្ពស់បំផុតនៅកម្ពុជា" ហើយនៅឆ្នាំ ២០២១ ក្នុងរយៈពេល ៦ខែចុងក្រោយនេះ ធនាគារ កាណាឌីយ៉ា ក៏បានទទួលពានរង្វាន់ចំនួនពីរ ក្នុងរះពេល ពីរឆ្នាំជាប់គ្នា គឺ "The Strongest Bank by Balance Sheet in Cambodia″ និង" Best Retail Bank in Cambodia 2021″។[3] ដោយឡែកនៅក្នុងរាជធានីភ្នំពេញវិញ ធនាគារកាណាឌីយ៉ា ក.អ ការិយាល័យកណ្តាល បានបង្កើតឡើងមុនគេ។ យើងខ្ញុំសូមអនុញ្ញាតលើកយកធនាគារកាណាឌីយ៉ា ក.អ ការិយាល័យកណ្តាល ដើម្បីធ្វើការសិក្សាស្រាវជ្រាវទាក់ទងទៅនិងសេវាប្រាក់បញ្ញើ-សន្សំ។ ធនាគារកាណាឌីយ៉ា ក.អ ចាប់កំណើតនៅ ១១ ខែវិច្ឆិកា ឆ្នាំ១៩៩១។ ក្រោមការដឹកនាំរបស់លោកអគ្គនាយកបូករួម និងការសហការណ៍រវាងបុគ្គលិកតាំង ពីថ្នាក់ក្រោម រហូតដល់ថ្នាក់គ្រប់គ្រងជាន់ខ្ពស់ទើបធ្វើអោយធនាគារកាណាឌីយ៉ា ក.អ ការិយាល័យកណ្តាល ទទួលបានប្រាក់ចំណេញយ៉ាងច្រើន។ លទ្ធផលល្អជាផ្លែផ្កាល្អបែបនេះគឺពឹងផ្អែកលើ យុទ្ធសាស្ត្រក្នុងការលក់ សេវាទាំងអស់របស់ធនាគារ ក្នុងនោះសេវាប្រាក់បញ្ញើ-សន្សំ គឺមានតួរនាទីសំខាន់ជាងគេក្នុងការរក្សានូវទុន បង្វិលផងដែរ។ដោយសារតែធនាគារកាណាឌីយ៉ា ក.អ ការិយាល័យកណ្តាល អនុវត្តន៍ស្របតាមគោលការណ៍ និតិវិធីច្បាប់រដ្ឋ និងយកក្រមសីលធម៌ជាគោលណ៍ទើបធ្វើអោយទទួលបានការជឿជាក់ពីអតិថិជនហើយធនាគារ ក៏ខិតខំពង្រីកសាខាជាច្រើនបន្ថែមរហូតក្លាយជាធនាគារ ដែលមានសាខាយ៉ាងច្រើននៅទូទាំងប្រទេសកម្ពុជា ដើម្បីបង្កជាលក្ខណៈងាយស្រួលជូនដល់អតិថិជនក្នុងតម្រូវការប្រើប្រាស់សេវា។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ការរីកចំរើនរបស់ធនាគារកាណាឌីយ៉ា ក.អ ការិយាល័យកណ្តាលគឺជាសមត្ថផលរបស់ថ្នាក់ដឹកនាំ និង ក្រុមបុគ្គលិកដែលបាន រិះរកយុទ្ធសាស្ត្រដឹកនាំ គ្រប់គ្រង ប្រតិបត្តិសហការណ៍តាមតួរនាទីរបស់ខ្លួន។ ចំពោះ សេវាប្រាក់បញ្ញើតួនាទី គឺជាសសរទ្រូងក្នុងការទ្រទ្រង់ទុនបង្វិលក្នុងធនាគារ ហើយត្រូវបានយកចិត្តទុកដាក់ យ៉ាងខ្លាំង។

- តើសេវាប្រាក់បញ្ញើសន្សំ របស់ធនាគារកាណាឌីយ៉ា ក.អ ការិយាល័យកណ្តាលមានដំណើរ ការយ៉ាងណាដូចម្តេច?មានប៉ុន្មានប្រភេទ?អ្វីខ្លះ?សេវាប្រាក់បញ្ញើសន្សំផ្តល់នូវអត្ថប្រយោជន៍ អ្វីខ្លះ ចំពោះអ្នកប្រើប្រាស់?
- តើអតិថិជនមានទស្សនៈទានដូចម្តេចខ្លះ ចំពោះធនាគារកាណាឌីយ៉ា?
- តើសេវាប្រាក់បញ្ញើ មានចំណុចល្អ និងចំណុចខ្វះខាតអ្វីខ្លះ?

[3] ដកស្រង់ពីគេហទំព័រ https://www.canadiabank.com.kh/news/award-article-1

## ៣. គោលបំណងនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ គឺមានគោលដៅស្វែងរកដំណោះស្រាយបញ្ហាមួយចំនួនដូចខាងក្រោម៖

- ស្វែងយល់ពីស្ថានភាព និងលក្ខណៈទូទៅរបស់ធនាគារកាណាឌីយ៉ា ក.អ ការិយាល័យកណ្តាល
- ស្វែងយល់ពីប្រសិទ្ធភាពការគ្រប់គ្រងសេវាកម្មប្រាក់បញ្ញើ-សន្សំរបស់ធនាគារកាណាឌីយ៉ាក.អ ការិយាល័យកណ្តាល
- ស្វែងយល់អំពីចំណុចខ្លាំង និងចំណុចខ្សោយរបស់ធនាគារកាណាឌីយ៉ា ក.អ ការិយាល័យ
- ស្វែងរកនីតិវិធីនៃការបើក និងបិទគណនី
- សុវត្ថិភាពក្នុងការដាក់ប្រាក់បញ្ញើ-សន្សំ
- ធ្វើការសន្និដ្ឋាន និងផ្តល់អនុសាសន៍ ។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

នៅក្នុងការសិក្សាស្រាវជ្រាវទៅលើប្រធានបទមួយ តែងតែមានដែនកំណត់នៃការសិក្សាស្រាវជ្រាវច្បាស់លាស់មួយទៅតាមពេលវេលាទំហំនៃប្រធានបទ និងប្រភេទទិន្នន័យដែលត្រូវយកមកសិក្សារស្រាវជ្រាវ។ អាស្រ័យហេតុនេះដោយសារតែផលិផលរបស់ធនាគារកាណាឌីយ៉ា ក.អ ការិយាល័យកណ្តាលមានច្រើន ដូចនេះហើយ នាំឲ្យការសិក្សាស្រាវជ្រាវមួយនេះផ្តោតសំខាន់លើទំហំនិងដែនកំណត់ ដែលលើកយកតែសេវាប្រាក់បញ្ញើ-សន្សំ ធនាគារកាណាឌីយ៉ា ក.អ ការិយាល័យកណ្តាល នៅចន្លោះ ឆ្នាំ ២០២០ ខែ មករា ដល់ ឆ្នាំ ២០២១ ខែ មិថុនា មកសិក្សាតែប៉ុណ្ណោះ។

## ៥. វិធីសាស្ត្រនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវឯកសារគឺជា ដំនើរការមួយ ដែលពាក់ព័ន្ធ និងការប្រតិបត្តិការនៃជំហាននិងនីតិវិធីជាច្រើនជាបន្តបន្ទាប់នៃវិធីសាស្ត្រស្រាវជ្រាវ។ ដូចនេះដើម្បីអាចប្រមូលទិន្នន័យមកចងក្រងជារបាយការណ៍បញ្ចប់ការសិក្សាសម្រាប់ ថ្នាក់បរិញ្ញាបត្រធនាគារ និងហិរវត្ថុចំពោះប្រធានបទខាងលើនេះឲ្យមានភាពត្រឹមត្រូវតាមក្បួនខ្នាត និងទទួលបានភាពជោគជ័យយើងខ្ញុំបានធ្វើការស្រាវជ្រាវតាមវិធីសាស្ត្រស្រាវជ្រាវដូចខាងក្រោមនេះ៖

### ៥.១. ប្រភេទនៃការស្រាវជ្រាវ

នៅក្នុងដំនើរការនៃការស្រាវជ្រាវអត្ថបទសិក្សាស្រាវជ្រាវនេះ យើងខ្ញុំបានធ្វើការប្រើប្រាស់នូវវិធីសាស្ត្រស្រាវជ្រាវតាមបែបគុណវិស័យ (Qualitative Method).ការស្រាវជ្រាវលក្ខណៈគុណវិស័យគឺជា ការស្រាវជ្រាវតាមបែប

វិទ្យាសាស្ត្រសង្គមដែលតាក់ទងនិងប្រមូល និងវិភាគទិន្នន័យដែលមិនមែនជាលេខ(Non-numerical Data).

ការជ្រើសយកវិធីសាស្ត្រស្រាវជ្រាវតាមបែនគុណវិស័យនេះ មកប្រើប្រាស់ក្នុងការសិក្សាស្រាវជ្រាវលើប្រធានបទមួយនេះ ដោយសារតែប្រធានបទខាងលើទាមទារឲ្យមានការបកស្រាយលើស្ថានភាពដែលកើតមានឡើងនៅក្នុងការធ្វើសេចក្ដីសម្រេចចិត្ត ហើយត្រូវធ្វើការវិភាគឲ្យស៊ីជម្រៅទៅលើបញ្ហាដែលកើតមានឡើងហើយទាំងនោះ។

## ៥.២. ប្រភេទនៃទិន្នន័យ

ដើម្បីឆ្លើយតបទៅនិងចំណោទបញ្ហាដែលបានលើកកើតឡើងខានលើ និងសម្រេចបាននូវគោលបំណងក្នុងការស្រាវជ្រាវទៅលើប្រធានបទមួយនេះ ដោយការប្រមូលទិន្នន័យ និងពត៌មានត្រូវបានធ្វើឡើងតាមរយះការប្រើប្រាស់ទិន្នន័យបន្ទាប់បន្សំ (Secondary Data) ដែលជានទិន្នន័យជំនួយ៉ាងសំខាន់ដែលធ្វើឲ្យយើងខ្ញុំកាន់តែយល់ច្បាស់ពីប្រាក់បញ្ញើសន្សំ។

- **ទិន្នន័យបន្ទាប់បន្សំ(Secondary Data)**៖ ជាទិន្នន័យទីពីរ ឬទិន្នន័យដែលមានស្រាប់។ទិន្នន័យដែលមានស្រាប់នេះ បានសង្ខេបនិងចងក្រងឡើងជារបាយការណ៍សិក្សាស្រាវជ្រាវ មួយនេះដែលយើងបានធ្វើការប្រមូលមកពីរប្រភពដូចជា៖
  - ទិន្នន័យដែលបានប្រើប្រាស់បកស្រាយ ជាទិន្នន័យទី២ មួយចំនួនដែលដកដស្រង់ចេញពីរប្រភពទិន្នន័យផ្សេងៗជាច្រើន។
  - ឯកសារផ្សេងៗ ដែលពាក់ព័ន្ធផ្ដល់ដោយធនាគារកាណាឌីយ៉ា ក.អ ការិយាល័យកណ្ដាលផ្ទាល់
  - ឯកសារស្រាវជ្រាវនានា តាមរយៈប្រព័ន្ធអ៊ីនធើណែត
  - ឯកសារដែលបានតាមរយៈការចូលគេហទំព័ររបស់ធនាគារ។

## ៥.៣. វិធីសាស្ត្រវិភាគទិន្នន័យ

នៅក្នុងវិធីសាស្ត្រវិភាគទិន្នន័យក្រុម យើងខ្ញុំបានជ្រើសរើសយកវិធីសាស្ត្រស្រាវជ្រាវតាមបែបគុណវិស័យ (Qualitative Method) គឺជាវិធីសាស្ត្រមួយដែលអនុវត្តទៅតាមដំណើរការដែលនាំមកនូវសភាព ឬបាតុភូតពិតៗដែត្រូវបានគេសង្កេត និងសិក្សានូវសេក្ដីអះអាង និងទ្រឹស្ដីទូទៅមួយចំនួន។ ការសិក្សារនេះបានធ្វើឡើងតាមរយៈការសម្ភាស ដោយមានការរៀបចំសំណួរជាដើម។ ដូចនេះយើងខ្ញុំជ្រើសរើសវិធីសាស្ត្រនេះដើម្បីប្រមូលពត៌មាន និងទិន្នន័យឲ្យបានគ្រប់គ្រាន់យកមកធ្វើការវិភាគ។

## ៦. សារៈសំខាន់នៃការស្រាវជ្រាវ

➢ **សារៈសំខាន់ចំពោះអ្នកសិក្សាស្រាវជ្រាវផ្ទាល់ ៖**

- បានសរសេរសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ
- យល់ដឹងពីការអនុវត្តផ្ទាល់ផ្សារភ្ជាប់ជាមួយទ្រឹស្តី
- ពង្រឹងចំនេះដឹងផ្នែកប្រាក់បញ្ញើ-សន្សំរបស់ខ្លួនក្នុងវិស័យធនាគារ

➢ **សារៈសំខាន់ចំពោះធនាគារៈ**

- ជំរុញផ្នែកពង្រីកសេវាប្រាក់បញ្ញើ-សន្សំដល់ធនាគារ
- ជួយបន្ថែមការផ្សព្វផ្សាយគ្រប់ផលិតផលនិងសេវាកម្មរបស់ធនាគារកាណាឌីយ៉ា ក.អ

➢ **សារៈសំខាន់ចំពោះសាធារណៈជនៈ**

- យល់ដឹងពីសេវាប្រាក់បញ្ញើ-សន្សំនៅធនាគារកាណាឌីយ៉ា ក.អ

➢ **ចំពោះនិស្សិតដទៃទៀត**

- ទុកជាឯកសារសម្រាប់ជួយបង្កើនចំណេះដឹង និងផ្តល់ជាបទពិសោធន៍ថ្មីៗដល់សិស្សនិស្សិតជំនាន់ក្រោយអំពីដំណើរការ នៃការចុះកម្មសិក្សា ព្រមទាំងប្រតិបត្តិការនិងយុទ្ធសាស្ត្ររបស់ធនាគារក្នុងការប្រមូលប្រាក់បញ្ញើ-សន្សំ។
- ទុកជាឯកសារ និងជួយផ្តល់ជាគន្លឹះសំរាប់អ្នកសិក្សាជំនាន់ក្រោយ។

➢ **ចំពោះសង្គមជាតិ**

- សង្គមយើងនឹងមានការរីកចម្រើននៅពេលដែលប្រជាជនមានការយល់ដឹងច្រើនអំពីវិស័យធនាគារ ទាំងការកម្ចីប្រាក់ដើម្បីពង្រីអាជីវកម្ម និងជាពិសេសគឺការទុកដាក់ប្រាក់ឲ្យមានសុវត្ថិភាព ព្រមទាំងបានការប្រាក់។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

សេចក្តីផ្តើម

↓

ជំពូកទី១៖ ការរំលឹកទ្រឹស្តី

↓

ជំពូកទី២៖ ស្ថានភាពទូទៅរបស់ធនាគាកាណាឌីយ៉ា ក.អ

↓

ជំពូកទី៣៖ សេវាកម្មប្រាក់បញ្ញើ-សន្សំរបស់ធនាគារការណាឌីយ៉ា ក.អ

↓

ជំពូកទី៤៖ ការវិភាគលើ SWOT

↓

សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

# ជំពូកទី១

# រំលឹកទ្រឹស្តី

## ១.១. ស្ថានភាពទូទៅរបស់ធនាគារពាណិជ្ជ

### ១.១.១. ប្រវត្តិនៃការកកើតធនាគារ

ប្រវត្តិនៃធនាគារបានចាប់ផ្តើមធនាគារគំរូដំបូងគឺ អ្នកជំនួញពិភពលោកដែលបានផ្តល់ប្រាក់កម្ចីគ្រាប់ធញ្ញជាតិដល់កសិករ និងពាណិជ្ជករ។ ក្រោយមកទៀតនៅប្រទេសក្រិចបុរាណ និងនៅចក្រភពរ៉ូមអ្នកផ្តល់ប្រាក់កម្ចីដែលមានមូលដ្ឋាននៅតាមប្រាសាទបានផ្តល់ប្រាក់កម្ចីខណៈពេលដែលទទួលយកប្រាក់បញ្ញើ-សន្សំ និង អនុវត្តការផ្លាស់ប្តូរប្រាក់។ បុរាណវិទ្យាពីសម័យនេះនៅប្រទេសចិននិងឥណ្ឌាបុរាណក៏បង្ហាញភស្តុតាងនៃការអោយខ្ចីប្រាក់ដែរ។

ពាក្យថាធនាគារ (Bank) គឺមានប្រភពមកពីពាក្យរបស់ប្រទេសអ៊ីតាលីថា Banca (នៅក្នុងសតវត្សរ៍ទី១៤) ដែលមានមូលដ្ឋានមកពីពាក្យអាឡឺម៉ង់ថា Bench ហើយក៏ប្រែជាភាសារអង់គ្លេសថា Bank មានន័យថាជាធាតុប្តូរប្រាក់។ រហូតមកដល់ដំណាច់ឆ្នាំ ២០២០ ធនាគារដែលមានអាយុកាលចំណាស់ជាងគេនៅតែដំណើរការ មានទីស្នាក់ការនៅទីក្រុង Naples ប្រទេសអ៊ីតាលីដែលបានដំណើរការតាំងពីឆ្នាំ ១៤៦៣ ។ នៅក្នុងយុគសម័យដ៏ទំនើបនេះធនាគារគេអោយឈ្មោះថា គ្រឹះស្ថានហិរញ្ញវត្ថុមួយដ៏សំខាន់ ដែលទទួលនូវប្រាក់បញ្ញើ-សន្សំ ផ្តល់នូវប្រាក់កំចី និងបំរើសេវាកម្មជាច្រើនទៀតជូនដល់អតិថិជន។[4]

### ១.១.២. និយមន័យធនាគារពាណិជ្ជ

ធនាគារពាណិជ្ជគឺ ស្ថាប័នហិរញ្ញវត្ថុដែលបើកបម្រើសេវា ធំទូលាយជាងស្ថាប័នហិញ្ញវត្ថុដទៃទៀត ហើយវាបានដើរតួរនាទីយ៉ាងសំខាន់នៅក្នុងការប្រតិបត្តិខ្លួនជាអន្តការី រវាងអ្នកត្រូវការមូលធន និងអ្នកខ្ចីប្រាក់ និងអ្នកដែលមានមូលធនលើស ផ្ញើប្រាក់នៅក្នុងធនាគារ។ម្យ៉ាងទៀត ធនាគារពាណិជ្ជ គឺជាអង្គភាពដែលស្វែងរកប្រាក់ចំណេញ ធនាគារពាណិជ្ជមានទ្រព្យសកម្ម និងបំណុលជាច្រើនប្រភេទ។[5]

## ១.២. លក្ខណៈទូទៅនៃសេវាប្រាក់បញ្ញើ-សន្សំ

### ១.២.១. និយមន័យ

ប្រាក់បញ្ញើ-សន្សំ គឺជាសេវាកម្មមួយប្រភេទរបស់ធនាគារក្នុងការទទួលយកមកពីអតិថិជន មករក្សាទុក

[4] ដកស្រង់ពីសៀវភៅសាស្ត្រាចារ្យ ងួន ហេង "រូបិយវត្ថុ និងធនាគារ",ទំព័រទី៥៨-៦១

[5] ដកស្រង់ពីសៀវភៅសាស្ត្រាចារ្យ ងួន ហេង "រូបិយវត្ថុ និងធនាគារ",ទំព័រទី៥៨

ដោយផ្តល់ការប្រាក់នូវអត្រាការប្រាក់ដែលបានកំណត់ណាមួយដល់អតិថិជន និងផ្តល់ជូនពួកគេវិញ នៅពេលដែលពួកគេត្រូវការ។ប្រាក់បញ្ញើ-សន្សំអាចហៅម្យ៉ាងទៀតថាជាបំណុលដែលធនាគារត្រូវសងទៅអតិថិជនវិញ។[6]

### ១.២.២. ប្រភេទនៃប្រាក់បញ្ញើ-សន្សំ

ប្រាក់បញ្ញើ-សន្សំ ត្រូវបានចែកចេញជាបីប្រភេទធំៗគឺ ប្រាក់បញ្ញើ ឬសញ្ជ័យ ប្រាក់បញ្ញើមិនមានកាលកំណត់ និងប្រាក់បញ្ញើមានកាលកំណត់។

#### ១.២.២.១. ប្រាក់បញ្ញើ-សន្សំសំច័យ

ប្រាក់បញ្ញើ-សន្សំសំច័យ គឺជាប្រភេទបញ្ញើ-សន្សំរបស់សហគ្រាសឬបុគ្គលផ្ញើនៅធនាគារ ដើម្បីឲ្យធនាគាររក្សាទុក និងបានមកវិញនូវការប្រាក់ក្នុងកម្រិតអត្រាទាបណាមួយ។ ចំពោះប្រាក់បញ្ញើ-សន្សំប្រភេទនេះមិនអាចប្រើប្រាស់មូលប្បទានប័ត្របានទេ គឺប្រើប្រាស់បានតែ Pass Book ដើម្បីធ្វើការដកប្រាក់តែប៉ុណ្ណោះ។

#### ១.២.២.២. ប្រាក់បញ្ញើ-សន្សំមិនមានកាលកំណត់

ប្រាក់បញ្ញើ-សន្សំមិនមានកាលកំណត់ គឺជាប្រភេទប្រាក់បញ្ញើ-សន្សំរបស់សហគ្រាស ឬបុគ្គលនៅធនាគារក្នុងគោលបំណងឲ្យធនាគារទុកជំនួស និងទូទាត់ជំនួសតាមតម្រូវការរបស់អ្នកផ្ញើ។ អតិថិជនអាចដកប្រាក់វិញបានគ្រប់ពេលវេលាដែលខ្លួន មានត្រូវការតាមរយៈការប្រើប្រាស់មូលប្បទានប័ត្រ។

#### ១.២.២.៣. ប្រាក់បញ្ញើ-សន្សំមានកាលកំណត់

ប្រាក់បញ្ញើ-សន្សំមានកាលកំណត់ គឺជាប្រភេទប្រាក់បញ្ញើ-សន្សំរបស់សហគ្រាស ឬបុគ្គលនៅធនាគារហើយអាចដកមកវិញទៅតាមពេលវេលាដែលបានកំណត់ជាក់លាក់ណាមួយ។ ប្រាក់បញ្ញើ-សន្សំប្រភេទនេះមិនអាចដកតាមតម្រូវការរបស់អតិថិជននោះទេ ចំណែកអត្រាការប្រាក់ គឺអាស្រ័យទៅតាមរយៈពេលនៃការដាក់ប្រាក់បញ្ញើ។[7]

## ១.៣. គោលបំណង និងមុខងារនៃប្រាក់បញ្ញើ-សន្សំ[8]

គោលបំណងដ៏សំខាន់នៃការទទួលយកប្រាក់បញ្ញើ-សន្សំ គឺជួយដល់ប្រព័ន្ធទូទាត់ និងផ្តល់ឥណទានទៅឲ្យបុគ្គល ឬអ្នកធ្វើជំនួញ ដែលត្រូវការពង្រីកអាជីវកម្ម ដោយសារតែពួកគេមានធានារ៉ាប់រងពីស្ថាប័នធានាប្រាក់បញ្ញើ-សន្សំ (ឬអាចប្រៀបបានទៅធានារ៉ាប់រងដែលចេញដោយសមាគមធានាមូលធនជាតិ)។

---

[6] ដកស្រងពីសៀវភៅសាស្ត្រាចារ្យ សួន ចំរើន "រូបិយវត្ថុ និងធនាគារ",ទំព័រទី១២

[7] ដកស្រងពីសៀវភៅសាស្ត្រាចារ្យ ងួន ហេង "រូបិយវត្ថុ និងធនាគារ",ទំព័រទី៧២

[8] ដកស្រង់ចេញពីសៀវភៅសារណាឆ្នាំ ២០១៧ និស្សិតឈ្មោះ ម៉ៅ ស្រីអូន និងស៊ិន ស៊ីណុច,ទំព័រទី៨

➢ **មុខងារទាំងប្រាំនៃប្រាក់បញ្ញើ-សន្សំ៖**

- ធានានូវសុវត្ថិភាពប្រាក់ និងឧបករណ៍ហិរញ្ញវត្ថុ៖ មានន័យថាការរក្សាលំនឹងនៃហិរញ្ញវត្ថុ និងរក្សាទំនុកចិត្តរបស់អតិថិជនទាំងក្នុង និងក្រៅប្រទេស។ ម្យ៉ាងទៀតពេលប្រព័ន្ធទូទាត់អាចទុកចិត្តបានហើយ ស្ថាប័ននានាក៏មានបំណងក្នុងការពង្រីកឥណទានដែលជម្រុញឲ្យសេដ្ឋកិច្ចមានការរីកចម្រើន។
- ផ្តល់នូវប្រសិទ្ធិភាព និងការប្រកួតប្រជែងនៅក្នុងប្រព័ន្ធហិរញ្ញវត្ថុ៖ គេបង្កើតគោលការណ៍មួយនេះឡើង ដើម្បីទប់ស្កាត់ការប្រមូលធនធានប្រាក់បញ្ញើ-សន្សំច្រើនហួសហេតុពេក ដែលធ្វើឲ្យគ្មានការប្រកួតប្រជែង ធ្វើឲ្យសាច់ប្រាក់មិនមានចរន្ត បណ្តាលឲ្យសេដ្ឋកិច្ចពឹងផ្អែកតែវិស័យផលិតកម្ម និងសេវាកម្មផ្សេងៗទៀត។
- រក្សានូវសុចរិតភាពនៃប្រព័ន្ធទូទាត់ជាតិ។
- ផ្តល់នូវស្ថេរភាពរូបិយវត្ថុ៖ ការគ្រប់គ្រងការបង្កើនសាច់ប្រាក់ជាតិ ដើម្បីផ្គត់ផ្គង់បរិមាណប្រាក់របស់ជាតិ ការគ្រប់គ្រងការជះឥទ្ធិពលនៃតម្លៃសាច់ប្រាក់ក្នុងការទូតទាត់ទំនិញ និងការទិញ-លក់មូលប័ត្ររដ្ឋាភិបាល។
- ការពារអតិថិជនពីការរលោភបំពានពីស្ថាប័នឥណទាន៖ ដើម្បីទប់ស្កាត់ការគេងចំណេញការប្រាក់ឥណទានពីស្ថាប័នឥណទាន ទៅលើអតិថិជន។

## ១.៤. គុណសម្បត្តិ និងគុណវិបត្តិនៃប្រាក់បញ្ញើ-សន្សំ

### ១.៤.១. ប្រាក់បញ្ញើ-សន្សំសំច័យ

➢ **គុណសម្បត្តិ**

- ងាយស្រួលក្នុងការប្រើប្រាស់សាច់ប្រាក់៖ អាចឲ្យលោកអ្នកដកប្រាក់បានគ្រប់ពេលវេលា។
- សុវត្ថិភាពសាច់ប្រាក់៖ បញ្ចៀសនូវការជ្រុះបាត់ ឬចោរលួច។
- មិនតម្រូវការប្រាក់តម្កល់ច្រើនសម្រាប់បើកគណនី៖ នេះជាចំណុចពិសេស និងផ្តល់ភាពងាយស្រួលដល់អតិថិជនក្នុងការបើកគណនី។
- អាចទូរទាត់វិក្កយបត្របាន និងសុវត្ថិភាព៖ អ្នកអាចទូរទាត់ការចាយវាយផ្សេងៗបាន និងធានាសុវត្ថិភាពប្រាក់អាប់មកវិញនូវប្រាក់ខ្លែងក្លាយ ក្រដាស់ប្រាក់រហែក។

➢ **គុណវិបត្តិ**

- អត្រាការប្រាក់ទទួលបានទាប៖ គណនីបញ្ញើ-សន្សំសំច័យវាទទួលបានការប្រាក់តិចជាងគណនីបញ្ញើ-សន្សំផ្សេងៗទៀត។

- អាចទាក់ទាញចំណាប់អារម្មណ៍ឲ្យលោកអ្នកចង់ចាយប្រាក់៖ ដោយសារភាពងាយស្រួលក្នុងការចាយបែបឆូតកាត និងភាពងាយស្រួលបញ្ជាទិញតាមប្រព័ន្ធអ៊ិនធឺណែត អាចបណ្តាលឲ្យលោកអ្នកចាយប្រាក់ច្រើន។
- ពិបាកក្នុងការដាក់ប្រាក់៖ ដោយសារប្រព័ន្ធម៉ាស៊ីនដាក់ប្រាក់មិនមានច្រើននៅតាមទីសាធារណៈ លោកអ្នកត្រូវធ្វើដំណើរឆ្ងាយទៅរកម៉ាស៊ីនដាក់ប្រាក់ ឬត្រូវទៅសាខាធនាគារដើម្បីដាក់ប្រាក់។
- ការដកប្រាក់មានការកំណត់៖ យើងមិនអាចដកប្រាក់ច្រើនលើកការកំណត់ ដែលធនាគារបានកំណត់ទេ។

## ១.៤.២. ប្រាក់បញ្ញើ-សន្សំមានកាលកំណត់

### ➢ គុណសម្បត្តិ

- ហានិភ័យទាប៖ គណនីនេះលោកអ្នកទទួលបានការប្រាក់ថេរ តាមពេលវេលាកំណត់ណាមួយ។ វាមានសុវត្ថិភាពណាស់សម្រាប់ការបាត់បង់សាច់ប្រាក់ ព្រោះធនាគារផ្តល់ភាពជឿជាក់ឲ្យលោកអ្នក។
- ត្រូវបានការពារពីហានិភ័យលើទីផ្សារ៖ ធនាគារផ្តល់ជូននៅអត្រាការប្រាក់ថេរ ដែលមាននៅក្នុងកិច្ចសន្យា បើទោះបីជាតម្លៃអត្រាការប្រាក់នៅលើទីផ្សារមានការធ្លាក់ចុះក៏ដោយ។

### ➢ គុណវិបត្តិ

- មិនមានសាច់ប្រាក់ច្រើននៅនឹងខ្លួន៖ ផលវិបាកបំផុតរបស់អតិថិជននោះគឺ ប្រាក់របស់ពួកគេត្រូវបានតម្កល់ទុកនៅក្នុងគណនី និងមិនអាចដកតាមតម្រូវការឡើយ ពុំនោះទេអតិថិជននឹងត្រូវខាតអត្រាការប្រាក់។
- មិនអាចដាក់ប្រាក់បន្ថែម៖ គណនីបញ្ញើ-សន្សំមានកាលកំណត់ មិនអនុញ្ញាតឲ្យ អតិថិជនដាក់ប្រាក់បន្ថែមទៅក្នុងគណនីនោះឡើយ។ បើអតិថិជនចង់បានអត្រាការប្រាក់បន្ថែម គឺតម្រូវឲ្យបើកគណនីមានកាលកំណត់ថ្មីមួយទៀត។
- មិនទទួលបានអត្ថប្រយោជន៍ពីទីផ្សារ៖ វាជាគុណវិបត្តិមួយនៅពេលអត្រាការប្រាក់កើនឡើង ប៉ុន្តែអត្រាការប្រាក់របស់គណនីមានកាលកំណត់នៅ ថេរជានិច្ច (មិនប្រែប្រួលទៅតាមអត្រាការប្រាក់ទីផ្សារ )។

- មិនទទួលបានការប្រាក់បន្ថែម៖អតិថិជនទទួលបានការប្រាក់ថេរប៉ុន្តែមានន័យថាអតិថិជន មិនអាចទទួលបានការប្រាក់បន្ថែមដូចគណនីបញ្ញើ-សន្សំនោះទេ។

## ១.៥. ហានិភ័យនៃការប្រើប្រាស់សេវាប្រាក់បញ្ញើ-សន្សំ

ហានិភ័យដែលអាចកើតមានឡើងទាក់ទងនឹងសេវាប្រាក់បញ្ញើ-សន្សំ ដែលធនាគារពាណិជ្ជត្រូវប្រឈមរួមមាន ហានិភ័យទីផ្សារ ហានិភ័យប្រតិបត្តិការ និងហានិភ័យសន្ទនីយភាព។

- ហានិភ័យទីផ្សារ៖ គឺជាហានិភ័យដែលបណ្ដាលមកពីបម្រែបម្រួលតម្លៃនៃទឹកប្រាក់ បញ្ញើ។ ហានិភ័យទីផ្សារចម្បងរបស់សេវាកម្មប្រាក់បញ្ញើ-សន្សំ គឺហានិភ័យអត្រាការប្រាក់ ដែលកើតមកពីអត្រាការប្រាក់លើប្រាក់បញ្ញើ-សន្សំនកម្រិតទាបដែលជាហេតុធ្វើ ឲ្យប្រាក់ចំណេញមានការថយចុះ។
- ហានិភ័យប្រតិបត្តិការ៖គឺជាហានិភ័យដែលធ្វើឲ្យដំណើរការប្រាក់បញ្ញើ-សន្សំមានបញ្ហា ដូចជា បញ្ហាបច្ចេកវិទ្យា ការបាត់បង់ទិន្នន័យអតិថិជន (Hacker)។ល។
- ហានិភ័យសន្ទនីយភាព៖ គឺជាហានិភ័យដែលកើតមានឡើងនៅពេលដែលធនាគារ មិនមានការបម្លែងសាច់ប្រាក់គ្រប់គ្រាន់ទៅតាមតម្រូវការដកប្រាក់របស់អតិថិជន។

## ១៦.. ប្រភេទការប្រាក់

### ១.៦.១. ការប្រាក់ទោល ( Simple Interest )

ការប្រាក់ទោលគឺជាការប្រាក់ដែលត្រូវបង់លើចំនួនទឹកប្រាក់ដើមឬចំនួនដែលបានខ្ចី។ ដើម្បីគណនាការប្រាក់នេះ តែពឹងផ្អែកទៅលើអថេបីយ៉ាងគឺ៖ ប្រាក់ដើម (ប្រាក់កម្ចី), អត្រាការប្រាក់ដែលបានកំណត់ និងចំនួនគ្រា។ ការប្រាក់ទោលមានរូបមន្ត៖

**រូបមន្តទី ១.១ រូបមន្តការប្រាក់ទោល**

$$SI = P_o (I) \times (n)$$

ដែល៖

- **SI** = ការប្រាក់ទោល
- $P_o$ = ប្រាក់ដើម ឬប្រាក់កម្ចី
- **I** = អត្រាការប្រាក់ក្នុងមួយគ្រា

- **n** = ចំនួនគ្រា[9]

ឧទាហរណ៍៖ អ្នកបានដាក់ប្រាក់ ១០០ ដុល្លារនៅក្នុងគណនីសន្សំមួយ ក្នុងរយៈពេល ១០ ឆ្នាំដែលផ្តល់អត្រាការប្រាក់ ៥% ក្នុងមួយឆ្នាំៗ ១០ឆ្នាំក្រោយមក តាមការគណនា អ្នកនឹងទទួល បានការប្រាក់៖

| ៥០$=$១០០ (0.0៥) $^{(១០)}$ |
|---|

សាច់ប្រាក់នាពេលអនាគត = FV = $១០០+ [$១០០(0.0៥) $^{(១០)}$] = $១៥០

**១.៦.២. ការប្រាក់សមាស** ( Compound Interest )

ជាប្រភេទការប្រាក់ ដែលគិតការប្រាក់លើការប្រាក់ជាបន្តបន្ទាប់។ ការប្រាក់ប្រភេទនេះតែង តែជួបប្រទះនៅលើឥណទាន ឬគណនីសន្សំដែលមានរយៈពេលចាប់ពីមួយឆ្នាំឡើងទៅ។ ការប្រាក់សមាសមានរូបមន្ត៖

***រូបមន្តទី ១.២ រូបមន្តការប្រាក់សមាស***

| $FV_n = P_o (1+I)^n$ |
|---|

ដែល៖

- $FV_n$= ចំនួនទឹកប្រាក់សរុបនៅចុងគ្រា
- $P_o$ = ប្រាក់ដើម
- I= អត្រាការប្រាក់ដែលបានកំណត់
- n = ចំនួនគ្រា[10]

ឧទាហរណ៍៖ អ្នកបានដាក់ប្រាក់ ១០០ ដុល្លារនៅក្នុងគណនីសន្សំមួយ ក្នុងរយៈពេល៥ឆ្នាំ ដែលផ្តល់អត្រាការប្រាក់ ៨% ក្នុងមួយឆ្នាំ។ នោះអ្នកនឹងទទួលបានការប្រាក់ $៨ នៅចុងឆ្នាំដំបូង អ្នកនឹងមានសាច់ប្រាក់ចំនួន $១០៨។ នៅឆ្នាំបន្ទាប់ $១០៨ របស់អ្នកនឹងកើនទៅ $១១៦ ៦៤។នេះហៅថា ការប្រាក់បង្កើតការប្រាក់។ វិធីគណនារកសាច់ប្រាប់នៅឆ្នាំទី២៖

$FV_2 = FV_1(1+i)=P_o(1+i)^2$

$108(1.08) = $100(1.08)² =$116.64

គណនាប្រាក់នៅឆ្នាំទី៣៖

$FV_3 =FV_1(1+i) + P_o(1+i)^3$

$108(1.08)(1.08) = $100(1.08)3 = $125.97

[9] ដកស្រង់ចេញពីសៀវភៅ "គណិតវិទ្យាសេដ្ឋកិច្ច"សម្រាប់ថ្នាក់ឆ្នាំមូលដ្ឋាន,សាស្ត្រាចារ្យ "ជា សែម" ឆ្នាំ ២០១៦-១០១៧,ទំព័រទី ២៥

[10] ដកស្រង់ចេញពីសៀវភៅ "គណិតវិទ្យាសេដ្ឋកិច្ច"សម្រាប់ថ្នាក់ឆ្នាំមូលដ្ឋាន ,សាស្ត្រាចារ្យ "ជា សែម" ឆ្នាំ ២០១៦-១០១៧,ទំព័រទី ៣៤

# ជំពូកទី ២

# ស្ថានភាពទូទៅរបស់ធនាគារ

## ២.១. ប្រវត្តិសង្ខេបរបស់ធនាគារកាណាឌីយ៉ា ក.អ[11]

ធនាគារកាណាឌីយ៉ា ក.អ គឺជាគ្រឹះស្ថានហិរញ្ញវត្ថុដែលឈានមុខគេនៅក្នុងប្រទេស កម្ពុជានាពេលបច្ចុប្បន្ន។ ធនាគារ កាណាឌីយ៉ា កអ ត្រូវបានបង្កើតឡើងនូវថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ១៩៩១ ដែលមាន ឈ្មោះថា "Canadia Gold & Trust Corporation Ltd." ដោយមានការចូលរួមរវាងភាគីកម្ពុជា កាណាដា និងធនាគារជាតិនៃកម្ពុជា។ រចនាសម្ព័ន្ធគ្រប់គ្រងរបស់ធនាគារគឺមានការចូលរួមពី បុគ្គលិកជំនាញៗពីធនាគារជាតិនៃកម្ពុជា និងម្ចាស់ភាគហ៊ុនទាំងសងខាងរវាងកម្ពុជានិងកាណាដា។ គោលដៅសំខាន់ៗរបស់ធនាគារ កាណាឌីយ៉ាគឺសំដៅទៅលើប្រតិបត្តិការមាស ដូចជាការ ផលិតមាស និងផ្តល់កម្ចីដល់ពាណិជ្ជករទាំងឡាយ។

នៅថ្ងៃ១៩ មេសា ១៩៩៣ - ធនាគារត្រូវបាន ប្តូរទៅជាធនាគារ កាណាឌីយ៉ា ដោយទទួលបានសិទ្ធជាធនាគារពាណិជ្ជកម្ម ពីធនាគារជាតិកម្ពុជា និងត្រូវបានចុះក្នុងបញ្ជីក្រសួងពាណិជ្ជកម្ម។

រហូតមកដល់ថ្ងៃទី១៦.ធ្នូ.២០០៣ ធនាគារត្រូវបាន ទទួលស្គាល់សារជាថ្មីថា ធនាគារកាណាឌីយ៉ាក.អ (CNB PLC)។

ចាប់តាំងពីឆ្នាំ១៩៩៨ ធនាគារបានក្លាយជាធនាគារក្នុងស្រុកដ៏ធំជាងគេ ជាមួយបណ្តាញដ៏ ធំជាងគេទូទាំងពិភពលោក ហើយមានការទទួលស្គាល់យ៉ាងមុតមាំពីសំណាក់ប្រជាជនក្នុងស្រុក ក៏ដូចជាក្រៅប្រទេស។ ធនាគារផ្តោតទៅលើទីផ្សារភាគហ៊ុនក្នុងការផ្តល់ប្រាក់កំចី ក៏ដូចជាការ ទទួលប្រាក់បញ្ញើ-សន្សំ។ ធនាគារផ្តល់ជូននូវសេវាកម្មហិរញ្ញវត្ថុនៅ ទីស្នាក់ការកណ្តាល និង គ្រប់៦៣សាខា ក្នុងទីក្រុងភ្នំពេញនិងបណ្តារខេត្តផ្សេងៗទៀត នៅក្នុងប្រទេសកម្ពុជា ។

## ២.២ ទស្សនៈវិស័យ បេសកម្ម គោលដៅនិងពាក្យស្លោករបស់ធនាគារកាណាឌីយ៉ាក.អ[12]

### ២.២.១. ទស្សនៈវិស័យ

ទស្សនៈវិស័យរបស់ធនាគារកាណាឌីយ៉ាក.អគឺ ធ្វើយ៉ាងណាដើម្បីអោយធនាគាររបស់ខ្លួនក្លាយទៅជាធនាគារដែលនាំមុខគេក្នុងវិស័យធនាគារ និងហិរញ្ញវត្ថុនៅប្រទេសកម្ពុជា។

### ២.២.២. បេសកម្ម

បេសកម្មរបស់ធនាគារ កាណាឌីយ៉ា ក.អ គឺផ្តល់នូវភាពទុកចិត្តនិងជាដៃគូដ៏ល្អបំផុតសំរាប់អតិថិជនតាមរយៈ

[11] ដកស្រង់ចេញពីគេហទំព័រសៀវភៅសារណា និស្សិតឈ្មោះ ប៊ុន ដាលីស និង បាន ប៊ុនលី, ឆ្នាំ ២០១៩,ទំព័រទី ៣២

[12] ដកស្រង់ចេញពីសៀវភៅរបាយការណ៍ប្រចាំ ២០១៨ របស់ធនាគារកាឌីយ៉ា,ទំព័រទី ១០

ការផ្តល់ជូននូវឥណទានសេវាប្រាក់បញ្ញើសេវាកម្មផ្សេងៗដែលជាមធ្យោបាយផ្តល់នូវភាពងាយដល់ភាគហ៊ុនជិកកម្មករ និយោជិក ព្រមទាំងសហគមន៍ទាំងអស់។

### ២.២.៣. គោលដៅ

គោលដៅរបស់ធនាគារ កាណាឌីយ៉ា ក.អ គឺផ្តល់ជូនអតិថិជននូវសេវាដ៏ល្អបំផុត តាមរយៈ បទពិសោធន៍ជាមួយអតិថិជន និងគុណភាពការងារសម្រាប់រយៈពេលវែងការបំពេញសេវាធនាគារ ដែលមានទំនាក់ទំនងជាមួយអតិថិជន។

### ២.២.៤. ពាក្យស្លោក

ធនាគារ កាណាឌីយ៉ា ក.អ ជាដៃគូដ៏ល្អបំផុតរបស់លោកអ្នក។

## ២.៣. ស្លាកសញ្ញា និងអត្ថន័យនៃស្លាកសញ្ញា

### ២.៣.១. ស្លាកសញ្ញា

រូបភាពទី១៖ស្លាកសញ្ញារបស់ធនាគារកាណាឌីយ៉ាក.អ

### ២.៣.២. អត្ថន័យនៃស្លាកសញ្ញា[13]

ស្លាកសញ្ញារបស់ធនាគារ កាណាឌីយ៉ា ក.អ បានកែច្នៃជារង្វង់មានលក្ខណៈស្រដៀងនឹងកាក់មាស និងអមដោយឈ្មោះរបស់ធនាគារ កាណាឌីយ៉ា ក.អ ជាអក្សរខ្មែរ ចិន និងអង់គ្លេស នៅខាងឆ្វេង រូបរង្វង់មូលពណ៌មាសគឺតំណាងឲ្យកាក់មាសចិន។ ធនាគារបានប្រើប្រាស់នូវរូប សញ្ញានេះដោយសារកាលពីមុនធនាគារ កាណាឌីយ៉ា ក.អ.ជាធនាគារដែលរកស៊ីលើរបរលក់ មាសសន្លឹក។ ក្នុងនោះរូបកាក់មាស គឺតំណាងឲ្យភាពរឹងមាំ និងស្ថិតស្ថេរគង់វង្សយូរអង្វែងនេះ សបញ្ជាក់ឲ្យឃើញពីស្ថានភាពហិរញ្ញវត្ថុដ៏រឹងមាំរបស់ធនាគារ កាណាឌីយ៉ា ក.អ។ ចំណែកឯផ្ទៃ ពណ៌មាស តំណាងឲ្យភាពរីកចំរើនឆ្ពោះទៅរកភាពជោគជ័យឥតឈប់ឈរក្នុង អាជីវកម្ម។

## ២.៤. ថ្នាក់ដឹកនាំក្រុមហ៊ុន[14]

សមាជិកក្រុមប្រឹក្សាភិបាលរបស់ធនាគារកាណាឌីយ៉ាក.អ ដែលបានកាន់តំណែងរួមមាន៖

[13] ដកស្រង់ចេញពីគេហទំព័រសៀវភៅសារណា និស្សិតឈ្មោះ ប៊ុន ដាលីស និង បាន ប៊ុនលី, ឆ្នាំ ២០១៩,ទំព័រទី ៣៣

[14] ដកស្រង់ចេញពីសៀវភៅរបាយការណ៍ប្រចាំ ២០២០ របស់ធនាគារកាណាឌីយ៉ា,ទំព័រទី ១៨

| | |
|---|---|
| ១. Dr. Pung Keav Se | Chairman |
| ២. Mr. Raymond Sia Say Guan | Chief Executive Officer/Executive Director |
| ៣. Mr. Vann Charles Chuon | Executive Director |
| ៤. Dr.Pung Carolyne | Executive Director |
| ៥. Mr. Chen Lee Yiaw Hui | Executive Director |
| ៦. Mr. Yee Con Long | Executive Director |
| ៧. Mr. Leow Ming Fong | Independent, Non-Executive Director |
| ៨. Mr. Peter Michael Buerger | Independent, Non-Executive Director |
| ៩. Mr. Jonh Meinhold | Independent, Non-Executive Director |
| ១០. Mr. Phong Nguyen | Independent, Non-Executive Director |
| ១១. Mr. Lim Socheat | Non-Executive Director |

## ២.៥. បណ្តាញប្រតិបត្តិការរបស់ធនាគារ កាណាឌីយ៉ា គអ.

គិតត្រឹមចុងឆ្នាំ ២០២០ ធនាគារកាណាឌីយ៉ា ក.អ មានសាខាចំនួន ៦៤ នៅទូទាំងប្រទេស ដើម្បីឲ្យអតិថិជនទៅទទួលយកសេវាកម្មមកប្រើប្រាស់។ ដែលក្នុងនោះនៅរាជធានីភ្នំពេញចំនួន ២៨ សាខាផងដែរ។ ធនាគារកាណាឌីយ៉ា ក.អ ក៏មានទីតាំងទូ អេធីអឹម ចំនួន ២៧០ កន្លែងនៅទូទាំងប្រទេស សម្រាប់ឲ្យអតិថិជនទៅធ្វើការដក់ប្រាក់។ ចំណែកម៉ាស៊ីនអេធីអឹមដើម្បីដាក់ប្រាក់ ធនាគារកាណាឌីយ៉ា ក.អ ក៏មាននៅតាមសាខានៅរាជធានីភ្នំពេញ និងសាខាតាមបណ្តារខេត្តមួយចំនួន។

## ២.៦. ទីតាំងរបស់ធនាគារកាណាឌីយ៉ា

រូបភាពទី២៖ ការិយាល័យកណ្តាលរបស់ធនាគារ កាណាឌីយ៉ា ក.អ



- ការិយាល័យកណ្តាលមានទីតាំងស្ថិតនៅអាគារលេខ៣១៥ ធានី-ភ្នំពេញ។

- Tel: (៨៥៥) ២៣ ៨៦៨ ២២២
- Email: canadia@canadiabank.com.kh
- Website: www.canadiabank.com.kh

## ២.៧. បណ្ដាសាខានៃធនាគារកាណាឌីយ៉ា ក.អ

គិតត្រឹមចុងឆ្នាំ ២០២០ ធនាគារកាណាឌីយ៉ា ក.អ មានសាខាចំនួន ៦៥ នៅទូទាំងប្រទេស ដើម្បីឲ្យអតិថិជនទៅទទួលយកសេវាកម្មមកប្រើប្រាស់។ ដែលក្នុងនោះនៅរាជធានីភ្នំពេញចំនួន ២៨ សាខាផងដែរ។ ធនាគារកាណាឌីយ៉ា ក.អ ក៏មានទីតាំងទូ អេធីអឹម ចំនួន ២៧០ កន្លែងនៅទូទាំងប្រទេស សម្រាប់ឲ្យអតិថិជនទៅធ្វើការដក់ប្រាក់។ ចំណែកម៉ាស៊ីនអេធីអឹមដើម្បីដាក់ប្រាក់ ធនាគារកាណាឌីយ៉ា ក.អ ក៏មាននៅតាមសាខានៅរាជធានីភ្នំពេញ និងសាខាតាមបណ្ដារខេត្តមួយចំនួន។[15]

## ២.៨. ផលិតផល និងសេវាកម្មរបស់ធនាគារកាណាឌីយ៉ា ក.អ[16]

➢ **សេវាកម្មប្រាក់បញ្ញើ-សន្សំ**

- គណនីសន្សំឬសំចៃយ (Saving Account)
- គណនីចរន្ត (Current Account)
- គណនីបញ្ញើមានកាលកំណត់ (Fixed Deposit Account)
- គណនីអនឡាញ (Online Account)
- គណនីវរជន (Elite Account)
- គណនីកុមារ (Junior Account)
- គណនីសន្សំសម្រាប់អាពាហ៍ពិពាហ៍ (Wedding Saving Account)
- គណនីបញ្ញើតាមផែនការ (Installment Deposit)

➢ **សេវាកម្មឥណទាន**

- ឥណទានផ្ទះ
- ឥណទានយានយន្ត
- ឥណទានមិនមានកម្រិត

➢ **សេវាកម្មផ្ទេរប្រាក់**

- សេវាកម្មផ្ទេរប្រាក់ក្នុងស្រុក

---

[15] ដកស្រង់ចេញពីសៀវភៅរបាយការណ៍ប្រចាំ ២០២០ របស់ធនាគារកាឌីយ៉ា,ទំព័រទី ១៦៨-១៧១

[16] ដកស្រង់ចេញពីគេហទំព័ររបស់ធនាគារកាឌីយ៉ា www.canadiabank.com.kh,chapter I "Personal-Accounts"

- សេវាកម្មដឹកជញ្ជូនប្រាក់
- SWIFT
- ម៉ាន់នីក្រាម
- គណនីអ៊ីប៊ែ្យរីវ័ន្ត

➢ **សេវាកម្មចាត់ចែង ឬទូរទាត់សាច់ប្រាក់**

- សេវាកម្មបើកប្រាក់បៀវត្សក្រុមហ៊ុន
- ប្តូររូបិយប័ណ្ណបរទេស
- សេវាធានា
- សេវាកម្មបង់ពន្ធ

➢ **កាតកាណាឌីយ៉ា**

- កាតអេធីអឹម
- កាតឥណពន្ធ
- កាតឥណទាន
- ស្តារកាត។

# ជំពូកទី៣

# ប្រាក់បញ្ញើ-សន្សំរបស់ ធនាគារ កាណាឌីយ៉ា ក.អ ទីស្នាក់ការកណ្តាល

## ៣.១ ផលិតផលប្រាក់បញ្ញើ[17]

### ៣.១.១. គណនីសំចៃ( Saving Account )

គណនីសំច័យរបស់ធនាគារ កាណាឌីយ៉ា ក.អ មានលក្ខណ:សាមញ្ញ ងាយស្រួលដែលអនុញ្ញាតិឲ្យអតិថិជនអាចសន្សំប្រាក់ពី ចំនួនតិចតួច និងអាចចាត់ចែងសាច់ប្រាក់នេះបានតាមតម្រូវការ និងគ្រប់ទីកន្លែង។ តាមរយ:សេវាធនាគារ តាមប្រព័ន្ធអ៊ីនធឺណែតប៉ែងឃីង ម៉ាស៊ីនដក-ដាក់ប្រាក់ 270 កន្លែងហើយ និងមានបណ្តាញទីស្នាក់ការកណ្តាលនិងគ្រប់ ៦៣សាខា ទូទាំងប្រទេសកម្ពុជា ។

#### ៣.១.១.១. លក្ខណៈពិសេសរបស់គណនីសំច័យ

- ដាក់ប្រាក់-ដកប្រាក់តាមទូរអេធីអឹម / ទូស៊ីអរអឹម (CRM) ឥតកំណត់
- សារជូនដំណឹងដោយស្វ័យប្រវត្តិរាល់ប្រតិបត្តិការគណនីតាមរយ:សេវាធនាគារតាមទូរស័ព្ទដៃ
- រីករាយជាមួយអត្រាការប្រាក់ប្រកួតប្រជែង
- រីករាយជាមួយការបញ្ចុះថ្លៃ លើការទូទាត់តាម QR ជាមួយដៃគូធនាគារ កាណាឌីយ៉ា
- ប្រភេទរូបិយប័ណ្ណះ ប្រាក់រៀល ប្រាក់ដុល្លារអាមេរិក ប្រាក់យ័ន និង ប្រាក់បាត
- រីករាយជាមួយការបញ្ចុះតម្លៃពិសេស ជាមួយដៃគូរបស់ធនាគារ កាណាឌីយ៉ា

#### ៣.១.១.២. លក្ខខណ្ឌក្នុងការបើកគណនីសំច័យ

**សម្រាប់បុគ្គល**

ក. ជនជាតិខ្មែរះ

- មានអាយុយ៉ាងតិច 18 ឆ្នាំ
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែនច្បាប់ដើមដែលមានសុពលភាព

ខ. ជនបរទេសះ

- មានអាយុយ៉ាងតិច 18 ឆ្នាំ
- លិខិតឆ្លងដែនច្បាប់ដើម និងមានសុពលភាព
- កិច្ចសន្យាជួលផ្ទះ ឬ
- លិខិតបញ្ជាក់ទីលំនៅ ចេញដោយពីអាជ្ញាធរ ឬ

[17] ដកស្រង់ចេញពីគេហទំព័ររបស់ធនាគារកាឌីយ៉ា www.canadiabank.com.kh,chapter I “Personal-Accounts”

- កិច្ចសន្យា / វិក្កយបត្រជួលសណ្ឋាគារស្នាក់នៅ ដែលមានរយៈពេលអប្បបរមា 6 ខែ ឬ
- កិច្ចសន្យាការងារ ឬ
- វិញ្ញាបនបត្រការងារ ឬ
- អាជ្ញាប័ណ្ណ / វិញ្ញាបនបត្រអាជីវកម្ម (ប្រសិនបើជាអាជីវកម្មផ្ទាល់ខ្លួន)
- ឯកសារមួយក្នុងចំណោមឯកសារភ្ជាប់ខាងលើ ត្រូវមានសុពលភាពយ៉ាងតិច 6ខែ។

**សម្រាប់ក្រុមហ៊ុន**

- ក្រុមហ៊ុនអាជីវកម្មដែលបានចុះបញ្ជីពាណិជ្ជកម្មស្របច្បាប់ក្នុងប្រទេសកម្ពុជា។
- វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្មអាជ្ញាប័ណ្ណអាជីវកម្មអនុស្សារណៈនិងលក្ខន្តិកៈក្រុមហ៊ុនសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល និងប័ណ្ណប៉ាតង់។
- មានអត្តសញ្ញាណប័ណ្ណឬលិខិតឆ្លងដែនរបស់សមាជិកក្រុមប្រឹក្សាភិបាលនិងម្ចាស់ភាគហ៊ុន។

### ៣.១.១.៣. លក្ខខណ្ឌក្នុងការបិទគណនី

ម្ចាស់គណនីត្រូវមកបិទដោយផ្ទាល់នៅធនាគារដោយភ្ជាប់មកជាមួយនូវអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន និងសៀវភៅធនាគារ ហើយអតិថិជនអាចដកប្រាក់ទាំងអស់ដែលមានក្នុង គណនីរបស់ពួកគាត់ (គិតថ្លៃសេវា 15ដុល្លារ ឬសមមូលរូបិយប័ណ្ណផ្សេង ប្រសិនបិទគណនីក្នុងរយៈពេលបីខែ គិតចាប់ពីថ្ងៃបើក)។

### ៣.១.១.៤. អត្រាការប្រាក់គណនីសំចៃ

- ចំពោះគណនីសន្សំជាប្រាក់ដុល្លារ អត្រាការប្រាក់ 0.25% បើសមតុល្យគណនីប្រចាំថ្ងៃ តូចជាង 1,000 ដុល្លារអាមេរិក 0.5% បើសមតុល្យគណនីប្រចាំថ្ងៃ ធំជាង ឬស្មើ 1,000 ដុល្លារអាមេរិក។
- ចំពោះគណនីសន្សំជាប្រាក់រៀល អត្រាការប្រាក់ ១.០០ ភាគរយ ក្នុងមួយឆ្នាំ
- ចំពោះគណនីសន្សំជាប្រាក់បាតថៃ អត្រាការប្រាក់ ០.០៥ ភាគរយក្នុងមួយឆ្នាំ

  សម្រាប់អត្រាការប្រាក់ខាងលើមិនមានការប្រែប្រួលទេនៅចន្លោះឆ្នាំ២០២០ ដល់ខែមិថុនា ឆ្នាំ ២០២១។

តារាងទី១ ៖បញ្ជីអត្រាការប្រាក់គណនីសំចៃ

| រូបិយប័ណ្ណ | ដុល្លារអាមេរិក | ប្រាក់រៀល | បាតថៃ |
|---|---|---|---|
| អត្រាការប្រាក់ប្រចាំឆ្នាំ | 0.២៥% < $១000<br>0.៥% > $១000 | ១.00% | 0.0៥% |

ប្រភពមកពីគេហទំព័រធនាគារកាណាឌីយ៉ាឆ្នាំ ២0២១

### ៣.១.១.៥. ការគណនាអត្រាការប្រាក់គណនីសំចៃ

រូបមន្ត

$$IN = (P1 \times r \times d \div 365) + (P2 \times r \times d \div 365) + (P3 \times r \times d \div 365) + \text{---} + (Pn \times r \times d \div 365)$$

- Pn ជាប្រាក់ដើមក្នុងគណនីប្រចាំថ្ងៃ
- IN ជាការប្រាក់ដែលអតិថិជនទទួលបាននៅចុងខែ
- r ជាអត្រាការប្រាក់
- d ជាចំនួនថ្ងៃដែលអតិថិជនដាក់ប្រាក់

ឧទាហរណ៍ៈ លោក តុលា បានបើកគណនីសន្សំ នៅក្នុងធនាគារកាណាឌីយ៉ានៅថ្ងៃទី 0១ ខែធ្នូ ឆ្នាំ ២0២0 ហើយនៅ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២0២0 សមតុល្យរបស់គាត់គឺ២0,000 ដុល្លារ។ គាត់បានធ្វើសកម្មភាពនៅក្នុងគណនីរបស់គាត់ នៅខែមករា ឆ្នាំ២0២១ដូចតទៅ៖

- នៅថ្ងៃ 0១-0១-២0២១ គណនីរបស់គាត់មាន២0,000 ដុល្លារ
- នៅថ្ងៃ ២៤-0១-២0២១ គាត់បានដាក់ប្រាក់ចំនួន១,000ដុល្លារ។ ដូច្នេះសមតុល្យរបស់គាត់គឺ ២១,000 ដុល្លារ
- នៅថ្ងៃ ៣0-0១-២0២១ គាត់បានដាក់ប្រាក់ចំនួន២,000ដុល្លារ។ ដូច្នេះសមតុល្យរបស់គាត់គឺ ២៣,000 ដុល្លារ

❖ វិធីសាស្ត្រគណនាការប្រាក់សំរាប់លោក តុលា ដែលគាត់ទទួលបានពីគណនីគាត់សំរាប់ខែ មករា ឆ្នាំ២0២១។

១. ពីថ្ងៃទី១ ដល់ ២៤ ខែមករា ឆ្នាំ២0២១ មានរយៈពេល ២៣ថ្ងៃ

- Interest=(២0,000×0.៥0%×២៣)÷៣៦៥= $៦.៣0

២. ពីថ្ងៃទី២៤ ដល់ ៣0 ខែមករា ឆ្នាំ២0២១ មានរយៈពេល ៦ថ្ងៃ

- Interest=(២១,000×0.៥0%×៦)÷៣៦៥= $១.៧៣

៣. ពីថ្ងៃទី៣0 ដល់ ៣១ ខែមករា ឆ្នាំ២0២១ មានរយៈពេល ១ថ្ងៃ

- Interest=(២៣,០០០×០.៥០%×១)÷៣៦៥= $០.៣២

❖ ចំនួនការប្រាក់សរុបសំរាប់ខែមករា ឆ្នាំ២០១១ គឺ $៦.៣០+$១.៧៣+$០.៣២= $៨.៣៥

ដោយគណនីនេះត្រូវបានគិតពន្ធក្នុងអត្រា ៦%

នាំឲ្យ ថ្លៃពន្ធដែលត្រូវបង់គឺ ៨,៣៥ x៦% =$០.៥

ដូច្នេះ ការប្រាក់ដែលអតិថិជនទទួលបាន=៨.៣៥-០.៥=$៧.៨៥

**៣.១.២. គណនីចរន្ត** ( Current Account)

គណនីចរន្ត ដែលអាចប្រើប្រាស់មូលប្បទានប័ត្រ សម្រាប់ការទូទាត់ ជំនួសឲ្យសាច់ប្រាក់សុទ្ធ ដែលមានជម្រើសរូបិយប័ណ្ណ ៤ ប្រភេទ(រូបិយប័ណ្ណជាប្រាក់រៀល ប្រាក់ដុល្លារអាមេរិក និងប្រាក់បាត-ថៃ) ជាពិសេសជួយសម្រួលដល់ប្រតិបត្តិការអាជីវកម្មរបស់លោកអ្នក ដោយការប្រើប្រាស់សេវាកម្មធនាគារតាមរយៈទូរស័ព្ទដៃ និងអ៊ីនធឺណែតប៉ែងយីង។

**៣.១.២.១. លក្ខណៈពិសេសរបស់គណនីចរន្ត**

- ដាក់ប្រាក់-ដកប្រាក់តាមទូរអេធីអឹម / ទូរស៊ីអរអឹម (CRM) ឥតកំណត់
- សារជូនដំណឹងដោយស្វ័យប្រវត្តិរាល់ប្រតិបត្តិការគណនីតាមរយៈសេវាធនាគារតាមទូរស័ព្ទដៃតាមប្រព័ន្ធអ៊ីនធឺណែត(Internet Banking) ប្រព័ន្ធទូរស័ព្ទ (Mobile Banking or Canadia Bank)
- ប្រើប្រាស់មូលប្បទានបត្រ
- រីករាយជាមួយការបញ្ចុះថ្លៃ លើការទូទាត់តាម QR ជាមួយដៃគូធនាគារ កាណាឌីយ៉ា
- ប្រភេទរូបិយប័ណ្ណ៖ ប្រាក់រៀល ប្រាក់ដុល្លារអាមេរិក ប្រាក់យ៉ន និងប្រាក់បាត
- រីករាយជាមួយការបញ្ចុះតម្លៃពិសេស ជាមួយដៃគូរបស់ធនាគារ កាណាឌីយ៉ា

**៣.១.២.២. លក្ខខណ្ឌក្នុងការបើកគណនីចរន្ត**

**សម្រាប់បុគ្គល**

ក. ជនជាតិខ្មែរ៖

- មានអាយុយ៉ាងតិច 18 ឆ្នាំ
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែនច្បាប់ដើមដែលមានសុពលភាព

ខ. ជនបរទេស៖

- មានអាយុយ៉ាងតិច 18 ឆ្នាំ
- លិខិតឆ្លងដែនច្បាប់ដើម និងមានសុពលភាព
- ស្ថានភាពទីលំនៅដែលភ្ជាប់មកជាមួយ៖

- កិច្ចសន្យាជួលផ្ទះ ឬ
- លិខិតបញ្ជាក់ទីលំនៅ ចេញដោយពីអាជ្ញាធរ ឬ
- កិច្ចសន្យា / វិក្កយបត្រជួលសណ្ឋាគារស្នាក់នៅ ដែលមានរយៈពេលអប្បបរមា 6 ខែ ឬ
- កិច្ចសន្យាការងារ ឬ
- វិញ្ញាបនបត្រការងារ ឬ
- អាជ្ញាប័ណ្ណ / វិញ្ញាបនបត្រអាជីវកម្ម (ប្រសិនបើជាអាជីវកម្មផ្ទាល់ខ្លួន)
- ឯកសារមួយក្នុងចំណោមឯកសារភ្ជាប់ខាងលើ ត្រូវមានសុពលភាពយ៉ាងតិច 6ខែ

**ខ.សម្រាប់ក្រុមហ៊ុន**

- ក្រុមហ៊ុនអាជីវកម្មដែលបានចុះបញ្ជីពាណិជ្ជកម្មស្របច្បាប់
- វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម អាជ្ញាប័ណ្ណអាជីវកម្មអនុស្សារណៈ និងលក្ខន្តិកៈ ក្រុមហ៊ុន សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល និងប័ណ្ណប៉ាតង់។
- មានអត្តសញ្ញាណប័ណ្ណឬលិខិតឆ្លងដែនរបស់សមាជិកក្រុមប្រឹក្សាភិបាលនិងម្ចាស់ភាគហ៊ុន។

### ៣.១.២.៣. លក្ខខណ្ឌក្នុងការបិទគណនីចរន្ត

ម្ចាស់គណនីត្រូវមកបិទដោយផ្ទាល់នៅធនាគារ ដោយភ្ជាប់មកជាមួយនូវអត្តសញ្ញាណប័ណ្ណ ឬលិខិឆ្លងដែន ឬអត្តសញ្ញាណប័ណ្ណ និងមូលប្បទានប័ត្រ ហើយអតិថិជនអាចដកប្រាក់ទាំងអស់ដែលមានក្នុងគណនីរបស់ពួកគាត់។

បញ្ជាក់៖ ក្នុងករណីអតិថិជនបិទគណនីក្នុងរយៈពេលបីខែ គិតចាប់ពីថ្ងៃបើក ក្រុមហ៊ុននិងគិតថ្លៃសេវា 15ដុល្លារ ឬសមមូលរូបិយប័ណ្ណផ្សេង ។

### ៣.១.២.៤. អត្រាការប្រាក់គណនីចរន្ត

ចំពោះគណនីចរន្តនេះ អតិថិជនមិនទទួលបានការប្រាក់ទេ។

### ៣.១.៣. គណនីមានកាលកំណត់ ( Fixed Deposit Account )

- គណនីមានកាលកំណត់អតិថិជននឹងទទួលបានអត្ថប្រយោជន៍ជាច្រើនបង្កើនប្រាក់របស់អ្នកតាមរយៈការដាក់ប្រាក់បញ្ញើ នៅធនាគារក្នុងស្រុកធំជាងគេ ដែលមានទំនុកចិត្ត ជាមួយអត្រាការប្រាក់ខ្ពស់ និង ភាពបត់បែននៃ រយៈពេលដាក់បញ្ញើតាមតម្រូវការ។គណនីមានកាលកំណត់មានបីជម្រើសគឺ៖
- Auto Roll Over: នៅពេលដល់កាលកំណត់ទាំងប្រាក់បញ្ញើ និងការប្រាក់នឹងក្លាយជាប្រាក់ញើនៅដើមការិយបរិច្ឆេទថ្មីដោយស្វ័យប្រវត្តិ។

- Auto Extended: នៅពេលដល់កាលកំណត់ប្រាក់បញ្ញើនឹងក្លាយជាប្រាក់បញ្ញើនៅដើមកាលបរិច្ឆេទថ្មីដោយស្វ័យប្រវត្តិ។
- Auto Interest Every month: ប្រាក់បញ្ញើដកបាននៅពេលដល់កាលកំណត់ ចំណែកឯការប្រាក់អាចដកបានរៀងរាល់ខែ (សម្រាប់តែគណនីជាប្រាក់ដុល្លារតែប៉ុណ្ណោះ)។

**៣.១.៣.១. លក្ខណៈពិសេសរបស់គណនីមានកាលកំណត់**

- អាចបើកបានបួនរូបិយប័ណ្ណមានដូចជា ប្រាក់រៀល និងប្រាក់ដុល្លារអាមេរិក ប្រាក់យេនចិន និងប្រាក់បាតថៃ។ ជម្រើសនៃរយៈពេលសន្សំមានច្រើន (១ខែ, ២ខែ, ៣ខែ, ៦ខែ, ១២ខែ, និង ២៤ខែ) ។
- រីករាយជាមួយនឹងអត្រាការប្រាក់ខ្ពស់ជាងគណនីសន្សំធម្មតា។
- ការប្រាក់ត្រូវបានបញ្ចូលដោយស្វ័យប្រវត្តិទៅក្នុងគណនីសំចៃឬគណនីចរន្តរបស់អតិថិជន។
- ជម្រើសក្នុងការដកប្រាក់ជារៀងរាល់ខែ ឬដកនៅពេលដល់កាលកំណត់។
- ជម្រើសក្នុងការបន្តពេលវេលាសន្សំដោយស្វ័យប្រវត្តិ (Auto-renewal)។
- រីករាយជាមួយអត្រាការប្រាក់ខ្ពស់
- ងាយស្រួលគ្រប់គ្រងសាច់ប្រាក់របស់លោកអ្នក ដោយជ្រើសរើសបន្តស្វ័យប្រវត្តិ ឬបិទនៅចុងគ្រា
- ផ្តល់ជូនប័ណ្ណឥណទានរហូតដល់ ១០០% នៃសមតុល្យប្រាក់បញ្ញើ ។

**៣.១.៣.២. លក្ខខណ្ឌក្នុងការបើកគណនីមានកាលកំណត់**

**សម្រាប់បុគ្គល**

- មានគណនីសំចៃ ឬគណនីចរន្តជាមួយធនាគារ កាណាឌីយ៉ា ក.អ ជាមុនសិន ។

ក. ជនជាតិខ្មែរ៖

- មានអាយុយ៉ាងតិច 18 ឆ្នាំ
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែនច្បាប់ដើមដែលមានសុពលភាព

ខ. ជនបរទេស៖

- មានអាយុយ៉ាងតិច 18 ឆ្នាំ
- លិខិតឆ្លងដែនច្បាប់ដើម និងមានសុពលភាព
- កិច្ចសន្យាជួលផ្ទះ ឬ
- លិខិតបញ្ជាក់ទីលំនៅ ចេញដោយពីអាជ្ញាធរ ឬ

- កិច្ចសន្យា / វិក្កយបត្រជួលសណ្ឋាគារស្នាក់នៅ ដែលមានរយៈពេលអប្បបរមា 6 ខែ ឬ
- កិច្ចសន្យាការងារ ឬ
- វិញ្ញាបនបត្រការងារ ឬ
- អាជ្ញាប័ណ្ណ / វិញ្ញាបនបត្រអាជីវកម្ម (ប្រសិនបើជាអាជីវកម្មផ្ទាល់ខ្លួន)
- ឯកសារមួយក្នុងចំណោមឯកសារភ្ជាប់ខាងលើ ត្រូវមានសុពលភាពយ៉ាងតិច 6ខែ។

**សម្រាប់ក្រុមហ៊ុន**

- ក្រុមហ៊ុនអាជីវកម្មដែលបានចុះបញ្ជីពាណិជ្ជកម្មស្របច្បាប់ក្នុងប្រទេសកម្ពុជា។
- វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្មអាជ្ញាប័ណ្ណអាជីវកម្មអនុស្សរណៈនិងលក្ខន្តិកៈក្រុមហ៊ុនសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល និងប័ណ្ណប៉ាតង់។
- មានអត្តសញ្ញាណប័ណ្ណឬលិខិតឆ្លងដែនរបស់សមាជិកក្រុមប្រឹក្សាភិបាលនិងម្ចាស់ភាគហ៊ុន។
- ដាក់ប្រាក់បញ្ញើដំបូងយ៉ាងតិច ៥០០ដុល្លារអាមេរិក សម្រាប់បើកគណនី ។
- មានគណនីសំចៃ ឬគណនីចរន្តជាមួយធនាគារ កាណាឌីយ៉ា ក.អ ជាមុនសិន ។

**៣.១.៣.៣. លក្ខខណ្ឌក្នុងការបិទគណនីមានកាលកំណត់**

ម្ចាស់គណនីត្រូវមកបិទដោយផ្ទាល់នៅធនាគារ ដោយភ្ជាប់មកជាមួយនូវអត្តសញ្ញាណប័ណ្ណ ឬលិខិឆ្លងដែន ឬអត្តសញ្ញាណប័ណ្ណនិងលិខិតបញ្ជាក់គណនីមានកាលកំណត់ ហើយអតិថិជនអាចដកប្រាក់ទាំងអស់ដែលមានក្នុងគណនីរបស់ពួកគាត់។

បញ្ជាក់៖ ក្នុងករណីអតិថិជនបិទគណនីមុនរយៈពេល២សប្តាហ៍នោះធនាគារនឹងធ្វើការពិន័យចំនួន១០ដុល្លារ។

**៣.១.៣.៤. អត្រាការប្រាក់គណនីមានកាលកំណត់** (ប្រចាំឆ្នាំ)

តារាងទី២ ៖ បញ្ជីអត្រាការប្រាក់គណនីបញ្ញើមានកាលកំណត់

| ប្រភេទ | ប្រាក់ដុល្លារអាមេរិក | | ប្រាក់រៀល | | ប្រាក់យ៉េន | ប្រាក់បាត |
|---|---|---|---|---|---|---|
| | នៅចុងគ្រា | នៅរៀងរាល់ខែ | នៅរៀងរាល់ខែ | នៅចុងគ្រា | | |
| 1 ខែ | 0.75% | 0.75% | 1.25% | 1.25% | 1.00% | 1.00% |
| 2 ខែ | 1.00% | 0.75% | 1.25% | 1.50% | មិនមាន | មិនមាន |
| 3 ខែ | 1.50% | 1.25% | 3.75% | 4.00% | 1.50% | 1.50% |

| | | | | | |
|---|---|---|---|---|---|
| 6 ខែ | 2.75% | 2.50% | 4.75% | 5.00% | 2.50% | 2.00% |
| 9 ខែ | 3.50% | 3.25% | 5.25% | 5.50% | មិនមាន | មិនមាន |
| 12 ខែ | 4.75% | 4.50% | 5.75% | 6.00% | 3.75% | 2.50% |
| 24 ខែ | 5.00% | 4.75% | 6.25% | 6.50% | មិនមាន | 3.00% |

ប្រភពមកពីគេហទំព័រធនាគារកាណាឌីយ៉ាឆ្នាំ ២០២១

[illegible]

| រូបិយប័ណ្ណ | ប្រាក់ដុល្លារអាមេរិក | ប្រាក់រៀល | ប្រាក់យ័ន | ប្រាក់បាត |
|---|---|---|---|---|
| ប្រាក់បញ្ញើដំបូង | USD500 | KHR 2,000,000 | RMB10,000 | THB40,000 |
| ជម្រើសទទួលការប្រាក់ | នៅរៀងរាល់ខែ ឬនៅចុងគ្រា | | នៅចុងគ្រា | |
| ជម្រើសបន្តដោយស្វ័យប្រវត្តិ | • បន្តប្រាក់ដើមដោយស្វ័យប្រវត្តិ ឬ<br>• បន្តប្រាក់ដើម និងការប្រាក់ដោយស្វ័យប្រវត្តិ<br>• បិទគណនីនៅពេលដល់កាលកំណត់ | | | |
| វិញ្ញាបនបត្រប្រាក់បញ្ញើ | ឥតគិតថ្លៃ | | | |
| បិទគណនី | គិតថ្លៃសេវា 10 ដុល្លារ ឬសមមូលរូបិយប័ណ្ណផ្សេង និងផ្តល់ជូនអត្រាការប្រាក់តាម គណនីសំចៃ ប្រសិនបិទគណនីក្នុងអំឡុង 2សប្តាហ៍ គិតចាប់ពីថ្ងៃបើក | | | |
| ដកប្រាក់ | មិនអនុញ្ញាតដកប្រាក់មុនកាលកំណត់ | | | |
| ការបើក ឬបិទគណនី | គ្រប់សាខាទាំងអស់របស់ធនាគារ កាណាឌីយ៉ា ក.អ | | | |

**៣.១.៣.៥. ការគណនាអត្រាការប្រាក់គណនីមានកាលកំណត់**

រូបមន្ត

IN=[(PxRxD)/៣៦៥ ឬ ៣៦៦]

ដោយ IN: ការប្រាក់ដែលអតិថិជនទទួលបាន

P: ប្រាក់ដើមរបស់អតិថិជន

R: អត្រាការប្រាក់

D: ចំនួនថ្ងៃដាក់ប្រាក់បញ្ញើ

ឧទាហរណ៍: លោក ឈឹង បុប្ផា បានបើកគណនីមានកាលកំណត់ រយៈពេល៣ខែគឺ ពីថ្ងៃទី១ ខែធ្នូ ឆ្នាំ ២០២១ ដល់ថ្ងៃទី១ខែមីនាឆ្នាំ២០២២។ ប្រាក់ដើមចំនួន៥០,០០០ដុល្លារ អត្រាការប្រាក់0.៥០%ក្នុងមួយឆ្នាំ។

**ករណីទី១:** លោកបានមកបិតគណនីមុនកាលបរិច្ឆេទ នៅថ្ងៃទី ១៤ ខែកុម្ភៈ ឆ្នាំ២០២២ ធនាគារនឹងផ្តល់ជូនអត្រាការប្រាក់ចំនួន០.៥០%សំរាប់រយៈពេល៧៦ថ្ងៃ(ពីថ្ងៃទី១ ខែធ្នូ ឆ្នាំ២០២១ ដល់ថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២២)

**គិតត្រឹមថ្ងៃទី ៣១ ខែមករា ឆ្នាំ២០២២**

- ការប្រាក់មុនបង់ពន្ធ = ៥០,000 x0.៥០% x៣១ / ៣៦៥ = $២១.២៣
- ចំនួនពន្ធ = ២១.២៣ x៦% = $១.២៧
- ការប្រាក់ក្រោយបង់ពន្ធ = ២១.២៣ - ១.២៧= $១៩.៩៦

**គិតត្រឹមថ្ងៃទី ១៤ ខែកុម្ភៈ ឆ្នាំ២០២២**

- ការប្រាក់មុនបង់ពន្ធ = ៥០,000 x0,៥០% x ៤៥ / ៣៦៥ = $៣០.៨២
- ចំនួនពន្ធ = ៣០.៨២ x ៦%= $១.៨៥
- ការប្រាក់ក្រោយបង់ពន្ធ = ៣០.៨២ - ១.៨៥ = $២៨.៩៧

**ការប្រាក់សរុប = ១៩.៩៦ + ២៨.៩៧ = $៤៨.៩៣**

**ករណីទី២:** លោកបានមកបិទគណនីនៅថ្ងៃបរិច្ឆេទ ថ្ងៃទី ១ ខែមីនា ឆ្នាំ២០២២

**គិតត្រឹមថ្ងៃទី ៣១ ខែមករា ឆ្នាំ២០២២**

- ការប្រាក់មុនបង់ពន្ធ = ៥០,000 x២.00% x៣១ / ៣៦៥ = $៨៤.៩៣
- ចំនួនពន្ធ = ៨៤.៩៣ x៦% = $៥.១០
- ការប្រាក់ក្រោយបង់ពន្ធ = ៨៤.៩៣ - ៥.១០ = $៧៩.៨៣

**គិតត្រឹមថ្ងៃទី ១៤ ខែកុម្ភៈ ឆ្នាំ២០២២**

- ការប្រាក់មុនបង់ពន្ធ = ៥០,000 x២.00% x ៤៥ / ៣៦៥ = $១២៣.២៨
- ចំនួនពន្ធ= ១២៣.២៨ x៦%= $៧.៣៩
- ការប្រាក់ក្រោយបង់ពន្ធ = ១២៣.២៨ - ៧.៣៩ = $១១៥.៨៨

**ការប្រាក់សរុប = $៧៩.៨៣ + $១១៥.៨៨ = $១៩៥.៧១**

### ៣.១.៤. គណនីអនឡាញ ( Online Account )

កាន់តែងាយស្រួល ក្នុងការបើកគណនីមានកាលកំណត់ ជាមួយធនាគារកាណាឌីយ៉ានៅលើ សេវា

ធនាគារតាមរយៈទូរសព្ទដៃ និង អ៊ីនធឺណែតប៉ែងឃើង ដែលផ្តល់ជូនការប្រាក់ខ្ពស់ ។

### ៣.១.៤.១. លក្ខណៈពិសេសរបស់គណនីអនឡាញ

- ងាយស្រួលបើកដោយខ្លួនឯងតាមរយៈសេវាធនាគារតាមប្រព័ន្ធអ៊ីនធឺណិត ឬទូរស័ព្ទដៃ
- រីករាយជាមួយអត្រាការប្រាក់ខ្ពស់
- ងាយស្រួលគ្រប់គ្រងសាច់ប្រាក់របស់លោកអ្នក ដោយជ្រើសរើសបន្តស្វ័យប្រវត្តិ ឬបិទនៅចុងគ្រា
- ផ្តល់ជូនប័ណ្ណឥណទានរហូតដល់ ១០០% នៃសមតុល្យប្រាក់បញ្ញើ ។
- ទទួលបានអត្រាការប្រាក់ខ្ពស់
- ផ្តល់ជូនដោយឥតគិតថ្លៃក្នុងការប្រើប្រាស់សេវាកម្មធនាគារតាមប្រព័ន្ធអ៊ីនធឺណេត និង ឧប ករណ៍សុវត្ថិភាព
- ផ្តល់ជូនអត្រាពិសេស សម្រាប់ផ្ទេរប្រាក់ក្នុងស្រុក និងក្រៅប្រទេស
- ថ្លៃសេវាពិសេស និងការបញ្ចុះតម្លៃលើប្រតិបត្តិការផ្សេងៗ។

### ៣.១.៤.២. លក្ខខណ្ឌក្នុងការបើកគណនីអនឡាញ

- ជាអតិថិជនប្រើប្រាស់សេវាធនាគារតាមប្រព័ន្ធអ៊ីនធឺណិត ឬទូរស័ព្ទដៃ ធនាគារ កាណាឌីយ៉ា
- ត្រូវមានគណនីសំច័យ គណនីចរន្ត គណនីធុរកិច្ចជាន់ខ្ពស់ ឬគណនីវរជន ដែលមានរូបិយប័ណ្ណដូចគ្នា ដើម្បីបើកគណនីមានកាលកំណត់ តាមរយៈសេវាធនាគារតាមទូរស័ព្ទដៃ ឬអ៊ីនធឺណិត

### ៣.១.៤៣. លក្ខខណ្ឌក្នុងការបិទគណនីអនឡាញ

ម្ចាស់គណនីត្រូវមកបិទដោយផ្ទាល់នៅធនាគារដោយភ្ជាប់មកជាមួយនូវអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន និងសៀវភៅធនាគារហើយអតិថិជនអាចដកប្រាក់ទាំងអស់ដែលមានក្នុងគណនីរបស់ពួកគាត់ (ក្នុងករណីអតិថិជនបិទគណនីមុនរយៈពេល៣ខែនោះធនាគារ នឹងធ្វើការពិន័យសេវាចំនួន៥០ដុល្លារ)។

### ៣.១.៤.៤. អត្រាការប្រាក់គណនីអនឡាញ

តារាងទី៣ ៖អត្រាការប្រាក់គណនីអនឡាញក្នុងមួយឆ្នាំ

| រយៈពេល | ប្រាក់ដុល្លារអាមេរិក | ប្រាក់រៀល | ប្រាក់បាត |
|---|---|---|---|
| | នៅចុងគ្រា | | |
| 1 ខែ | 0.75% | មិនមាន | 1.00% |

| | | | |
|---|---|---|---|
| 2 ខែ | 1.00% | មិនមាន | មិនមាន |
| 3 ខែ | 1.50% | 4.00% | 1.50% |
| 6 ខែ | 2.75% | 5.00% | 2.00% |
| 9 ខែ | 3.50% | មិនមាន | មិនមាន |
| 12 ខែ | 4.75% | 6.00% | 2.50% |
| 24 ខែ | 5.00% | 6.50% | 3.00% |

ប្រភពមកពីគេហទំព័រធនាគារកាណាឌីយ៉ាឆ្នាំ ២០២១

**[illegible]**

| រូបិយប័ណ្ណប្រាក់បញ្ញើដំបូង | ប្រាក់ដុល្លារអាមេរិក | ប្រាក់រៀល | ប្រាក់បាត |
|---|---|---|---|
| | USD 500 | KHR 2,000,000 | THB 40,000 |
| ជម្រើសទទួលការប្រាក់ | នៅចុងគ្រា | | |
| ជម្រើសបន្តដោយស្វ័យប្រវត្តិ | • ទទួលការប្រាក់រៀងរាល់ខែ ឬ<br>• ទទួលការប្រាក់នៅចុងគ្រា<br>• ផ្តល់ជូននៅពេលបិទគណនី | | |
| វិញ្ញាបនបត្រប្រាក់បញ្ញើ | មិនមាន | | |
| បិទគណនី | ផ្តល់ជូនអត្រាការប្រាក់តាមគណនីសំចៃ ប្រសិនបើបិទគណនីមុនកាលកំណត់ | | |
| ដកប្រាក់ | មិនអនុញ្ញាតដកប្រាក់មុនកាលកំណត់ | | |
| ការបើក ឬបិទគណនី | សេវាធនាគារតាមប្រព័ន្ធអ៊ីនធឺណិត ឬទូរស័ព្ទដៃ | | |

**៣.១.៥. គណនីវរជន** ( Elite Account )

គណនីវរជន របស់ធនាគារ កាណាឌីយ៉ា ត្រូវបានរចនាឡើងជាពិសេសសម្រាប់រូបវន្តបុគ្គល ជាវរជន ។ ក្នុងនាមជាអតិថជនវរជនក្រៅពី អត្រាការប្រាក់គួរជាទីគាប់ចិត្ត លោកអ្នកនឹងទទួលបាននូវកញ្ចប់ សេវាកម្មហិរញ្ញវត្ថុដ៏ពិសេស និងអាទិភាព ដែលបម្រើជូនដោយមន្ត្រីទំនាក់ទំនងផ្ទាល់ រួមអត្ថប្រយោជន៍បន្ថែមជាច្រើនដែលផ្តល់ដោយកាណាឌីយ៉ាគ្រុប ។

**៣.១.៥.១. លក្ខណៈពិសេសរបស់គណនីវរជន**

- ប្រើប្រាស់សេវាកម្មធនាគារនៅ Private Banking Lounge ដោយឥតគិតថ្លៃ
- ជាប្រភេទគណនីចរន្តទទួលបានការប្រាក់ខ្ពស់

- ផ្តល់ជូន ប័ណ្ណវរជន ដោយឥតគិតថ្លៃ
- សេវាធនាគារតាមទូរស័ព្ទដៃ ដោយឥតគិតថ្លៃ
- ដាក់ប្រាក់-ដកប្រាក់តាមទូរអេធីអឹម / ទូរស៊ីអរអឹម (CRM) ឥតកំណត់
- សារជូនដំណឹងដោយស្វ័យប្រវត្តិរាល់ប្រតិបត្តិការគណនីតាមរយៈសេវាធនាគារតាមទូរស័ព្ទដៃ
- ផ្តល់ជូនអត្រាប្តូរប្រាក់ពិសេសត
- មន្ត្រីទំនាក់ទំនងសម្រាប់គណនីផ្ទាល់ខ្លួន
- ផ្តល់ជូនលេខគណនីពិសេស នៅផ្នែក Private Banking
- ផ្តល់ជូននូវកញ្ចប់ប្រតិបត្តិការផ្ទេរប្រាក់ក្រៅប្រទេស និងប្រតិបត្តិការធនាគារផ្សេងៗជាពិសេសសម្រាប់គណនីវរជន។
- រីករាយជាមួយការបញ្ចុះថ្លៃលើការទូទាត់តាម QR ជាមួយដៃគូធនាគារ កាណាឌីយ៉
- រីករាយជាមួយការបញ្ចុះតម្លៃពិសេស ជាមួយដៃគូរបស់ធនាគារ កាណាឌីយ៉ា
- ផ្តល់ជូនប័ណ្ណឥណទាន Infinite VISA

**៣.១.៥.២. លក្ខខណ្ឌក្នុងការបើកគណនីវរជន**

ប្រាក់បញ្ញើដំបូង USD ២០,000 ឬ KHR ៨0,000,000

ក. ជនជាតិខ្មែរ៖

- មានអាយុយ៉ាងតិច 18 ឆ្នាំ
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែនច្បាប់ដើមដែលមានសុពលភាព

ខ. ជនបរទេស៖

- មានអាយុយ៉ាងតិច 18 ឆ្នាំ
- លិខិតឆ្លងដែនច្បាប់ដើម និងមានសុពលភាព
- កិច្ចសន្យាជួលផ្ទះ ឬ
- លិខិតបញ្ជាក់ទីលំនៅ ចេញដោយពីអាជ្ញាធរ ឬ
- កិច្ចសន្យា / វិក្កយបត្រជួលសណ្ឋាគារស្នាក់នៅ ដែលមានរយៈពេលអប្បបរមា 6 ខែ ឬ
- កិច្ចសន្យាការងារ ឬ
- វិញ្ញាបនបត្រការងារ ឬ
- អាជ្ញាប័ណ្ណ / វិញ្ញាបនបត្រអាជីវកម្ម (ប្រសិនបើជាអាជីវកម្មផ្ទាល់ខ្លួន)

- ឯកសារមួយក្នុងចំណោមឯកសារភ្ជាប់ខាងលើ ត្រូវមានសុពលភាពយ៉ាងតិច ៦ខែ។

**៣.១.៥.៣. លក្ខខណ្ឌក្នុងការបិទគណនីចរន្ត**

- ចំពោះគណនីសន្សំរវជនះម្ចាស់គណនីត្រូវមកបិទដោយផ្ទាល់ភ្ជាប់មកជាមួយនូវអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន និងសៀវភៅធនាគារហើយអតិថិជនអាចដកប្រាក់ទាំងអស់ដែលមានក្នុងគណនីរបស់ពួកគាត់។
- បញ្ជាក់៖ ក្នុងករណីអតិថិជនបិទគណនីមុនរយៈពេល៣ខែ នោះធនាគារនឹងធ្វើការផាកពិន័យចំនួន៥០ដុល្លារ។

**៣.១.៥.៤. អត្រាការប្រាក់គណនីចរន្ត**

- សម្រាប់ការដាក់ប្រាក់ក្រោម ២០,០០០ ដុល្លារ មិនទទួលបានការប្រាក់នោះទេ។
- សម្រាប់ការដាក់ប្រាក់ស្មើឬក្រោម ១០០,០០០ ដុល្លា ទទួលបានការប្រាក់ ១.០០ភាគរយក្នុងមួយឆ្នាំ។
- សម្រាប់ការដាក់ប្រាក់លើស ១០០,០០០ ដុល្លា ទទួលបានការប្រាក់ ១.២០ភាគរយក្នុងមួយឆ្នាំ។
- ០%ប្រសិនសមតុល្យគណនីតូចជាង ៨០,០០០,០០០ រៀល
- ១.០០%ប្រសិនសមតុល្យគណនី ធំជាង; តូចជាង ឬស្មើ ២០០,០០០,០០០ រៀល
- ១.២០%ប្រសិនសមតុល្យគណនី ធំជាង ២០០,០០០,០០០ រៀល; ៨០០,០០០,០០០,០០០រៀល

**៣.១.៦. គណនីកុមារ** (Junior Account)

ក្នុងនាមជាមាតាបិតា ការចាប់ផ្តើមសន្សំប្រាក់មានសារៈសំខាន់ណាស់សម្រាប់អនាគតរបស់បុត្រធីតាលោកអ្នក ។ គណនីកុមាររបស់ធនាគារ កាណាឌីយ៉ា ផ្តល់ជូននូវអត្រាការប្រាក់ខ្ពស់ជាងគេ ដែលអាចជួយសម្រេចគោលដៅសន្សំប្រាក់សម្រាប់អនាគតបុត្រធីតារបស់លោកអ្នក ហើយជាពិសេសទៀត វាបានធ្វើឲ្យកុមារយល់ដឹងអំពីទម្លាប់នៃការសន្សំប្រាក់តាំងពីក្មេងវ័យ។

**៣.១.៦.១. លក្ខណៈពិសេសរបស់គណនីកុមារ**

- រីករាយជាមួយអត្រាការប្រាក់ គួរជាទីពេញចិត្ត
- បញ្ចុះតម្លៃរហូត 5% លើថ្លៃសិក្សានៅសាលាអន្តរជាតិកាណាដា
- បញ្ចុះតម្លៃរហូត 25% សម្រាប់ចូលទស្សនាសួន ដាណ្ឌស័រ នៅក្រុងរណបជ្រោយចង្វារ
- បញ្ចុះតម្លៃពិសេសសម្រាប់ក្លឹប CIS Roller Dome

- ផ្តល់ជូនប័ណ្ណឥណទាន ដល់ឪពុក-ម្តាយ ឬអាណាព្យាបាល របស់កុមារ រហូតដល់ 80% នៃសមតុល្យប្រាក់បញ្ញើ ។

**៣.១.៦.២. លក្ខខណ្ឌក្នុងការបើកគណនីកុមារ**

- កុមារដែលមានអាយុក្រោម ឬស្មើ១៥ឆ្នាំ អាចបើកគណនីនេះបាន។
- កុមារ ត្រូវមានសំបុត្រកំណើត និងរូបថត ២សន្លឹក ។
- មាតាបិតា/អាណាព្យាបាល អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន។
- ដាក់ប្រាក់បញ្ញើដំបូងយ៉ាងតិច ២០០ដុល្លារ សម្រាប់បើកគណនី។

**៣.១.៦.៣. លក្ខខណ្ឌក្នុងការបិទគណនីកុមារ**

- កុមារ
- កុមារមានអាយុ 16 ឆ្នាំ ឬក្រោម
- សំបុត្រកំណើត
- មាតាបិតា/អាណាព្យាបាល

ក. ជនជាតិខ្មែរ៖

- មានអាយុយ៉ាងតិច 18 ឆ្នាំ
- លិខិតឆ្លងដែនច្បាប់ដើមនិងមានសុពលភាព

ខ. ជនបរទេស៖

- មានអាយុយ៉ាងតិច 18 ឆ្នាំ
- លិខិតឆ្លងដែនច្បាប់ដើម និងមានសុពលភាព
- ឯកសារបញ្ជាក់ពីការស្នាក់នៅ ឬមានវត្តមាននៅក្នុងប្រទេសកម្ពុជា ជាង១៨២ ថ្ងៃក្នុងរយៈពេល ១២ ខែនៅក្នុងឆ្នាំនៃប្រតិទិនឆ្នាំ ដូចជា៖
- ស្ថានភាពទីលំនៅដែលភ្ជាប់មកជាមួយ៖
- កិច្ចសន្យាជួលផ្ទះ ឬ
- លិខិតបញ្ជាក់ទីលំនៅ ចេញដោយពីអាជ្ញាធរ ឬ
- កិច្ចសន្យា / វិក្កយបត្រជួលសណ្ឋាគារស្នាក់នៅ ដែលមានរយៈពេលអប្បបរមា 6 ខែ ឬ
- កិច្ចសន្យាការងារ ឬ
- វិញ្ញាបនបត្រការងារ ឬ
- អាជ្ញាប័ណ្ណ / វិញ្ញាបនបត្រអាជីវកម្ម (ប្រសិនបើជាអាជីវកម្មផ្ទាល់ខ្លួន)

- ឯកសារមួយក្នុងចំណោមឯកសារភ្ជាប់ខាងលើត្រូវមានសុពលភាពយ៉ាងតិច ៦ ខែ

**៣.១.៦.៤. អត្រាការប្រាក់កុមារ**

- អត្រាការប្រាក់ ៥.៥០ ភាគរយក្នុងមួយឆ្នាំ។

តារាងទី៤ ៖អត្រាការប្រាក់គណនីកុមារ

| | |
|---|---|
| រូបិយប័ណ្ណ | ប្រាក់ដុល្លារអាមេរិក |
| អត្រាការប្រាក់ប្រចាំឆ្នាំ | 5.50% |
| ការប្រាក់ផ្តល់ជូន | រៀងរាល់ឆ្នាំ |
| ប្រាក់បញ្ញើដំបូង | USD200 |
| ប្រាក់បញ្ញើអប្បបរមា | USD2,000 |
| ប័ណ្ណឥណទាន VISA/Master | • ប័ណ្ណធម្មតា៖ 13 ដុល្លារអាមេរិក/មួយឆ្នាំ<br>• ប័ណ្ណមាស៖ 28 ដុល្លារអាមេរិក/មួយឆ្នាំ |
| កម្រៃសេវាផ្ទេរប្រាក់អចិន្ត្រៃយ៍ (ចុះឈ្មោះ, ប្រតិបត្តិការ) | ឥតគិតថ្លៃ |
| សៀវភៅសំច័យ (ថ្មី ឬបន្ត) | ឥតគិតថ្លៃ (សម្រាប់តែការស្នើសុំប៉ុណ្ណោះ) |
| សេវាធនាគារតាមប្រព័ន្ធទូរស័ព្ទដៃ | ឥតគិតថ្លៃ |
| ដាក់ប្រាក់ | ដាក់ប្រាក់អតិបរមា 100,000 ដុល្លារអាមេរិកក្នុងមួយឆ្នាំ |
| ដកប្រាក់ | • អនុញ្ញាតិដកប្រាក់បានម្តងក្នុងមួយខែ<br>• គណនីកុមារនឹងប្តូរទៅជាគណនីសំច័យ នៅពេលបុត្រធីតាលោកអ្នកអាយុគ្រប់ 18ឆ្នាំ |
| ការបើក ឬបិទគណនី | គ្រប់សាខាទាំងអស់របស់ធនាគារ កាណាឌីយ៉ា ក.អ |

ប្រភពមកពីគេហទំព័រធនាគារកាណាឌីយ៉ាឆ្នាំ ២០២១

**៣.១.៧. គណនីសន្សំសម្រាប់អាពាហ៍ពិពាហ៍** ( Wedding Saving Account )

បង្កើតអនុស្សាវរីយ៍មិនអាចបំភ្លេចបាន ដោយចាប់ផ្តើមសន្សំប្រាក់ពីពេលនេះ សម្រាប់ថ្ងៃដ៏សំខាន់របស់លោកអ្នក គណនីសន្សំសម្រាប់អាពាហ៍ពិពាហ៍ជួយលោកអ្នកក្នុងការរៀបចំផែនការថវិកា និងផ្តល់ជូននូវកញ្ចប់អត្ថប្រយោជន៍ពិសេស សម្រាប់ថ្ងៃអាពាហ៍ពិពាហ៍របស់លោកអ្នក។

### ៣.១.៧.១. លក្ខណៈពិសេសរបស់គណនីអាពាហ៍ពិពាហ៍

- រីករាយជាមួយអត្រាការប្រាក់ខ្ពស់គួរជាទីពេញចិត្ត
- ទទួលបានកញ្ចប់អាពាហ៍ពិពាហ៍រហូតដល់ 2,999 ដុល្លារអាមេរិក ជាមួយកាណាឌីយ៉ាគ្រុប ដូចជា ជួលសាលអាពាហ៍ពិពាហ៍កោះពេជ្រ សណ្ឋាគារតារា Pandora/Bering Brands…អត្ថប្រយោជន៍ផ្សេងៗជាច្រើនទៀត។
- រីករាយជាមួយកញ្ចប់ថតរូបសម្រាប់អាពាហ៍ពិពាហ៍
- ផ្តល់ជូនប័ណ្ណឥណទាន រហូតដល់ 80% នៃសមតុល្យប្រាក់បញ្ញើ

### ៣.១.៧.២. លក្ខខណ្ឌក្នុងការបើកគណនីអាពាហ៍ពិពាហ៍

ក. ជនជាតិខ្មែរ៖

- មានអាយុយ៉ាងតិច 18 ឆ្នាំ
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែនច្បាប់ដើមដែលមានសុពលភាព

ខ. ជនបរទេស៖

- មានអាយុយ៉ាងតិច 18 ឆ្នាំ
- លិខិតឆ្លងដែនច្បាប់ដើម និងមានសុពលភាព
- កិច្ចសន្យាជួលផ្ទះ ឬ
- លិខិតបញ្ជាក់ទីលំនៅ ចេញដោយពីអាជ្ញាធរ ឬ
- កិច្ចសន្យា / វិក្កយបត្រជួលសណ្ឋាគារស្នាក់នៅ ដែលមានរយៈពេលអប្បបរមា 6 ខែ ឬ
- កិច្ចសន្យាការងារ ឬ
- វិញ្ញាបនបត្រការងារ ឬ
- អាជ្ញាប័ណ្ណ / វិញ្ញាបនបត្រអាជីវកម្ម (ប្រសិនបើជាអាជីវកម្មផ្ទាល់ខ្លួន)
- ឯកសារមួយក្នុងចំណោមឯកសារភ្ជាប់ខាងលើ ត្រូវមានសុពលភាពយ៉ាងតិច 6ខែ។

### ៣.១.៧.៣. លក្ខខណ្ឌក្នុងការបិទគណនីអាពាហ៍ពិពាហ៍

ម្ចាស់គណនីត្រូវមកបិទដោយផ្ទាល់នៅធនាគារ ដោយភ្ជាប់មកជាមួយនូវ អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន និងសៀវភៅធនាគារ ឬអត្តសញ្ញាណប័ណ្ណ និងលិខិតបញ្ជាក់គណនី អាពាហ៍ពិពាហ៍ ហើយអតិថិជនអាចដកប្រាក់ទាំងអស់ដែលមានក្នុងគណនីរបស់ពួកគាត់។

### ៣.១.៧.៤. អត្រាការប្រាក់គណនីអាពាហ៍ពិពាហ៍

តារាងទី៥ ៖អត្រាការប្រាក់គណនីអាពាហ៍ពិពាហ៍

| | |
|---|---|
| រូបិយប័ណ្ណ | ប្រាក់ដុល្លារអាមេរិក |
| អត្រាការប្រាក់ប្រចាំឆ្នាំ | 2.88% |
| ការប្រាក់ផ្តល់ជូន | រៀងរាល់ខែ |
| ប្រាក់បញ្ញើដំបូង | USD500 |
| ប្រាក់បញ្ញើអប្បបរមា | USD500 |
| កម្រៃសេវាផ្ទេរប្រាក់ជាអចិន្ត្រៃយ៍(ចុះឈ្មោះ, ប្រតិបត្តិការ) | ឥតគិតថ្លៃ |
| សៀវភៅសំចៃយ (ថ្មី ឬបន្ត) | ឥតគិតថ្លៃ (សម្រាប់តែការស្នើសុំប៉ុណ្ណោះ) |
| សេវាធនាគារតាមប្រព័ន្ធទូរស័ព្ទដៃ | ឥតគិតថ្លៃ |
| បិទគណនី | គិតថ្លៃសេវា 50 ដុល្លារ ឬសមមូលរូបិយប័ណ្ណផ្សេង ប្រសិនបិទគណនីរយៈពេលបីខែ គិតចាប់ពីថ្ងៃបើក |
| ដកប្រាក់ | • មិនគិតថ្លៃសេវា សម្រាប់ការដកប្រាក់រហូតដល់ ពីរដង ក្នុងមួយខែ<br>• 0.1% ឬអប្បបរមា 10 ដុល្លារអាមេរិក សម្រាកដកប្រាក់លើសចំនួនកំណត់ម្តង។ |
| រូបិយប័ណ្ណ | ប្រាក់ដុល្លារអាមេរិក |

ប្រភពមកពីគេហទំព័រធនាគារកាណាឌីយ៉ាឆ្នាំ ២០២១

### ៣.១.៨. គណនីបញ្ញើតាមផែនការ (Installment Deposit Account)

គណនីបញ្ញើតាមផែនការ ជម្រុញការតាំងចិត្តដ៏មុតមាំ ដើម្បីសម្រេចគោលដៅហិរញ្ញវត្ថុនាពេលអនាគតរបស់លោកអ្នក ដែលមានរយៈពេលពី 1 ឆ្នាំ រហូតដល់ 3 ឆ្នាំ ។

#### ៣.១.៨.១.លក្ខណៈពិសេសរបស់គណនីបញ្ញើតាមផែនការ

- រីករាយជាមួយអត្រាការប្រាក់ គួរជាទីពេញចិត្ត ពីមួយឆ្នាំរហូតដល់បីឆ្នាំ
- ផ្តល់ជូនវិញ្ញាបនបត្រប្រាក់បញ្ញើ និងតារាងសន្សំប្រាក់ ដោយឥតគិតថ្លៃ
- ផ្តល់ជូនប័ណ្ណឥណទាន រហូតដល់ 80% នៃសមតុល្យប្រាក់បញ្ញើ ។

#### ៣.១.៨.២. លក្ខខណ្ឌក្នុងការបើកគណនីបញ្ញើតាមផែនការ

ក. ជនជាតិខ្មែរ៖

- មានអាយុយ៉ាងតិច 18 ឆ្នាំ
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែនច្បាប់ដើមដែលមានសុពលភាព

ខ. ជនបរទេសៈ

- មានអាយុយ៉ាងតិច 18 ឆ្នាំ
- លិខិតឆ្លងដែនច្បាប់ដើមនិងមានសុពលភាព
- កិច្ចសន្យាជួលផ្ទះ ឬ
- លិខិតបញ្ជាក់លំនៅដ្ឋានចេញដោយអាជ្ញាធរ ឬ
- កិច្ចសន្យា / វិក័យប័ត្រជួលសណ្ឋាគារស្នាក់នៅ ដែលមានរយៈពេលអប្បបរមា 6 ខែ
- កិច្ចសន្យាការងារ ឬ
- វិញ្ញាបនបត្រការងារ ឬ
- អាជ្ញាប័ណ្ណ / វិញ្ញាបនបត្រអាជីវកម្ម (ប្រសិនបើជាអាជីវកម្មផ្ទាល់ខ្លួន)
- ឯកសារមួយក្នុងចំណោមឯកសារភ្ជាប់ខាងលើត្រូវមានសុពលភាពយ៉ាងតិច 6 ខែ

**៣.១.៨.៣ លក្ខខណ្ឌក្នុងការបិទគណនីបញ្ញើតាមផែនការ**

- ម្ចាស់គណនី ត្រូវមកបិទដោយផ្ទាល់នៅធនាគារដោយភ្ជាប់មកជាមួយនូវអត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែន និងសៀវភៅធនាគារ ឬអត្តសញ្ញាណប័ណ្ណ និងលិខិតបញ្ជាក់គណនី។
- ការបិទគណនីមុន៣ខែត្រូវបង់កម្រៃសេវា១៥ដុល្លារ។
- ពេលបិទគណនីអតិថិជនអាចដកប្រាក់ទាំងអស់ដែលមានក្នុងគណនីរបស់ពួកគាត់។
- រាល់ការបិទគណនីមុនកាលកំណត់ ការប្រាក់នឹងត្រូវបានគិតដូចគណនីសន្សំ។

**៣.១.៨.៤.អត្រាការប្រាក់បញ្ញើតាមផែនការ**

តារាងទី៦ ៖ បញ្ជីអត្រាការប្រាក់គណនីបញ្ញើតាមផែនការ

| ប្រភេទ | ដុល្លារអាមេរិក(គិតជាឆ្នាំ) | ប្រាក់រៀល (គិតជាឆ្នាំ) |
|---|---|---|
| 1 ឆ្នាំ | 3.75% | 5.00% |
| 2 ឆ្នាំ | 4.50% | 6.00% |
| 3 ឆ្នាំ | 5.00% | 7.00% |
| ការប្រាក់ផ្តល់ជូន | នៅចុងគ្រា ឬផ្តល់ជូននៅពេលបិទគណនី | |
| សន្សំប្រចាំខែអប្បបរមា | 50 ដុល្លារអាមេរិក ឬ 200,000 រៀល | |

| | |
|---|---|
| បិទគណនី | គិតថ្លៃសេវា 10 ដុល្លារ ឬសមមូលរូបិយប័ណ្ណផ្សេង និងផ្តល់ជូនអត្រាការប្រាក់តាម គណនីសំចៃយប្រសិនបិទគណនីក្នុងអំឡុងបីខែ គិតចាប់ពីថ្ងៃបើក |
| ប័ណ្ណឥណទានVISA /master | • ប័ណ្ណធម្មតា៖ 13 ដុល្លារអាមេរិក/មួយឆ្នាំ<br>• ប័ណ្ណមាស៖ 28 ដុល្លារអាមេរិក/មួយឆ្នាំ |
| សេវាធនាគារតាមប្រព័ន្ធទូរស័ព្ទដៃ | ឥតគិតថ្លៃ |

ប្រភពមកពីគេហទំព័រធនាគារកាណាឌីយ៉ាឆ្នាំ ២០២១

**៣.១.៨.៦. ការគណនាអត្រាការប្រាក់បញ្ញើតាមផែនការ**

តាមរូបមន្ត៖ ការប្រាក់ទទួលបាននៅចុងគ្រា = IN1+ IN2+IN3+...+Inn

ឧទាហរណ៍: P = ១០០

t = ១ឆ្នាំ

r = ៣.៧៥%

នាំឲ្យ IN១= (១០០ x៣.៧៥% x៣១)/៣៦៥ = ០.៣២

IN២= (២០០ x៣.៧៥% x២៨)/៣៦៥ =០.៥៨

IN៣= (៣០០ x៣.៧៥% x៣១)/៣៦៥ =០.៩៦

IN៤= (៤០០ x៣.៧៥% x៣០)/៣៦៥ = ១.២៣

IN៥= (៥០០ x៣.៧៥% x៣១)/៣៦៥ = ១.៥៩

IN៦= (៦០០ x៣.៧៥% x៣០)/៣៦៥ = ១.៨៥

IN៧= (៧០០ x ៣.៧៥% x៣១)/៣៦៥ = ២.២៣

IN៨= (៨០០ x ៣.៧៥% x៣១)/៣៦៥ = ២.៥៥

IN៩= (៩០០ x ៣.៧៥% x៣០)/៣៦៥ = ២.៧៧

IN១០= (១,០០០ x ៣.៧៥% x៣១)/៣៦៥ = ៣.១៨

IN១១= (១,១០០ x ៣.៧៥% x៣០)/៣៦៥ = ៣.៣៩

IN១២= (១.២០០ x ៣.៧៥% x៣១)/៣៦៥ = ៣.៨២

- ការប្រាក់ដែលគាត់ទទួលមុនពេលបង់ពន្ធគឺ = $២៤.៤៧
- ពន្ធដែលគាត់ត្រូវបង់គឺ = ២៤.៤៧ x៦% = $១.៤៧

ដូច្នេះ ការប្រាក់ដែលគាត់ទទួលបាននៅចុងឆ្នាំគឺ ២៤.៤៧-១.៤៧= $២៣

**សំគាល់**៖ ពន្ធលើការប្រាក់ នៃប្រាក់បញ្ញើទាំងអស់គឺ អត្រា ៦ភាគរយ។[18]

### ៣.២. យុទ្ធសាស្ត្រចែកចាយ

យុទ្ធសាស្ត្រចែកចាយ គឺជាយុទ្ធសាស្ត្រមួយដែលយកមកអនុវត្តន៍ដើម្បីទាញយកចំណែកទីផ្សារឲ្យបានកាន់តែធំ។ ដើម្បីទាញយកចំណែកទីផ្សារសេវាប្រាក់បញ្ញើ-សន្សំឲ្យបានកាន់តែធំ ធនាគារ កាណាឌីយ៉ា ក.អ ទីស្នាក់ការ២កណ្តាល បានបង្កើតនូវទីតាំងការិយាល័យដើម្បីបំរើសេវាជូនអតិថិជនគ្រប់លំដាប់ថ្នាក់ដែលមានរហូតទៅដល់នៅទូទាំងព្រះរាជាណាចក្រកម្ពុជា។បណ្តាញការិយាល័យផ្តល់សេវាទាំងនោះមានដូចជា៖ ការិយាល័យ ទីស្នាក់ការកណ្តាល ដែលមានទីតាំងស្ថិតនៅក្នុងរាជធានីភ្នំពេញ ការិយាល័យសាខាខេត្ត-ក្រុងរាជធានីមាន ៦៥ ការិយាល័យ។

#### ៣.២.១. ការជ្រើសរើសទីតាំងការិយាល័យ ទីស្នាក់ការកណ្តាល

ធនាគារ កាណាឌីយ៉ា ក.អ បានជ្រើសរើសទីតាំងការិយាល័យទីស្នាក់ការកណ្តាល ដែលស្ថិតនៅតំបន់ទីប្រជុំជនព្រមទាំងមានសក្តានុពល និងមានសុវត្ថិភាព។ ការជ្រើសរើសទីតាំងនេះដោយសារតែវាមានលក្ខណៈពិសេសដូចខាងក្រោម៖

- ស្ថិតនៅចំកណ្តាលរាជធានីភ្នំពេញ។
- មានបរិយាកាស និងទេសភាពល្អ។
- ជាទីកន្លែងប្រជុំជន។
- ជាកន្លែងបណ្តុំទៅដោយក្រុមហ៊ុន អង្គការ សណ្ឋាគារ ភោជនីយដ្ឋាន និងផ្សារទំនើបៗជាច្រើនដែលនៅព័ទ្ធជុំវិញ។
- មានមនុស្សធ្វើដំណើរឆ្លងកាត់ច្រើន។

#### ៣.២.២. ការបែងចែកផលិតផលសេវាកម្ម

ធនាគារកាណាឌីយ៉ាក.អ ទីស្នាក់ការកណ្តាល បានធ្វើការបែងចែកបញ្ជូនផលិតផលសេវាកម្មដោយផ្ទាល់ទៅអ្នកប្រើប្រាស់ ឬអតិថិជនរបស់ខ្លួន។ ការបែងចែកនេះធ្វើឡើងតាមរយៈដូចជា៖

- ការិយាល័យរបស់ធនាគារ គឺតម្រូវឲ្យអតិថិជនមកទទួលសេវាកម្មដោយផ្ទាល់ នៅការិយាល័យរបស់ធនាគារ។
- ការដើរលក់តាមផ្ទះ ៖ គឺធនាគារមានភ្នាក់ងារបុគ្គលិក សម្រាប់ធ្វើការចុះដើរលក់សេវា កម្មតាម

[18] ដកស្រង់ចេញពី គេហទំព័រធនាគារកាណាឌីយ៉ាwww.canadiabank.com.kh

ផ្ទះ ដើម្បីផ្តល់ភាពងាយស្រួលដល់អតិថិជន ដែលពុំមានពេលវេលា និងយានជំនិះក្នុងការមក ទទួលសេវាកម្មដោយផ្ទាល់នៅការិយាល័យរបស់ធនាគារ។

## ៣.៣ យុទ្ធសាស្ត្រជំរុញលក់

ធនាគារ កាណាឌីយ៉ា ក.អ បានយកចិត្តទុកដាក់ជាខ្លាំងទៅលើការជំរុញការលក់របស់ខ្លួនដោយធនាគារធ្វើការអភិវឌ្ឍនូវកម្មវិធីផ្សព្វផ្សាយដែលមានភាពជាក់លាក់សម្រាប់ផលិតផល និងទីផ្សារនីមួយៗ។ ការជំរុញការលក់នេះហើយ គឺជាចលករមួយដ៏សំខាន់អាចបើកផ្លូវឲ្យធនាគារបានធ្វើដំណើរឆ្ពោះទៅរកភាពរុងរឿង។ ការជំរុញការលក់សេវាកម្មរបស់ធនាគារ កាណាឌីយ៉ា ក.អ ត្រូវបានអនុវត្តន៍តាមរយៈ ៤ ចំណុចរួមមាន៖

### ៣.៣.១.ការផ្សព្វផ្សាយតាមប្រព័ន្ធ Media

ការផ្សព្វផ្សាយនេះ ត្រូវបានរៀបចំឡើងដោយនាយកដ្ឋានម៉ាឃីតធីង នៅការិយាល័យកណ្តាលរបស់ធនាគារ កាណាឌីយ៉ា ក.អ ។ រូបភាពនៃការផ្សព្វផ្សាយនេះមានដូចជា៖ ការផ្សព្វផ្សាយតាមទូរទស្សន៍ វិទ្យុ ទស្សនាវដ្តី កាសែត ការធ្វើសន្និសិទកាសែត។

ការផ្សព្វផ្សាយបែបនេះ អាចធ្វើឡើងនៅពេលដែលមានការបង្កើតការិយាល័យថ្មី ឬ នៅពេលដែលមានការអភិវឌ្ឍន៍បន្ថែមលើផលិតផលចាស់ ឬបង្កើតផលិតផលថ្មីក្នុងគោលបំណងជូនដំណឹងដល់អតិថិជនឲ្យបានដឹង និងស្គាល់។

### ៣.៣.២. ការផ្សព្វផ្សាយជាសាធារណៈ

ការផ្សព្វផ្សាយជាសាធារណៈ ត្រូវបានធ្វើឡើងដើម្បីឲ្យសាធារណៈជនបានស្គាល់ធនាគារកាន់តែច្បាស់។ ហើយការផ្សព្វផ្សាយបែបនេះ ត្រូវបានអនុវត្តតាមរយៈដូចខាងក្រោម៖

- ចូលរួមក្នុងកម្មវិធីមនុស្សធម៌ផ្សេងៗ កម្មវិធីសិក្ខាសិលា ឬការតាំងពិព័រណ៍ស្តីពីការងារ
- ការធ្វើទំនាក់ទំនងជាមួយអាជ្ញាធរគ្រប់ជាន់ថ្នាក់ ចូលរួមប្រជុំតាមភូមិ ឃុំ ខេត្ត និងថ្នាក់ជាតិ។
- ធនាគារ កាណាឌីយ៉ា បានផ្តល់ឱកាសដល់និស្សិតបានចុះអនុវត្តន៍កម្មសិក្សា និងធ្វើការងារដែលជាលក្ខណៈផ្សព្វផ្សាយផង និងជួយសង្គមផង។

### ៣.៣.៣. ការផ្សព្វផ្សាយដោយផ្ទាល់

ការផ្សព្វផ្សាយដោយផ្ទាល់ ឬការលក់ដោយផ្ទាល់ គឺជាការផ្សព្វផ្សាយមួយ ដែលត្រូវអនុវត្តន៍ដោយភ្នាក់ងារលក់ផ្ទាល់របស់ធនាគារ ការងារនេះត្រូវបានធ្វើជាប្រចាំថ្ងៃដោយមានធ្វើជាកំណត់ត្រាច្បាស់លាស់ ដើម្បីងាយស្រួលក្នុងការតាមដាននូវរាល់សកម្មភាពការងារ។ ក្នុងការលក់ដោយផ្ទាល់នេះ ភ្នាក់ងារបុគ្គលិកបានចុះទៅជួបអតិថិជនដោយផ្ទាល់ ដើម្បីសិក្សាស្វែងយល់ពីអតិថិជន គោលបំណងធ្វើការបែងចែកទីផ្សារ ព្រមទាំង

យល់ដឹងពី តម្រូវការរបស់អតិថិជន ហើយឈានដល់ដំណាក់កាលលើកទឹកចិត្ត និងជំរុញឲ្យអតិថិជនប្រើប្រាស់នូវផលិតផល និងសេវាកម្មរបស់ធនាគារ កាណាឌីយ៉ា ក.អ។

### ៣.៣.៤. ការផ្សព្វផ្សាយតាមប្រព័ន្ធអេឡិចត្រូនិច

ការផ្សព្វផ្សាយតាមប្រព័ន្ធអេឡិចត្រូនិចរបស់ ធនាគារកាណាឌីយ៉ា ក.អត្រូវបានអនុវត្តន៍ឡើងតាមរយៈដូចជា៖

- តាមរយៈគេហទំព័រដែលមានឈ្មោះថា www.canadiabank.com.kh ដែលត្រូវរៀបចំឡើងសម្រាប់ផ្តល់ព័ត៌មានផលិតផល និង សេវាកម្ម ជូនអតិថិជន និងសាធារណៈជន។
- តាមរយៈ Facebook និង Instagram ដែលត្រូវរៀបចំឡើងសម្រាប់ផ្តល់ព័ត៌មានថ្មីៗ ច្បាស់លាស់ត្រឹមត្រូវ និងទាន់ហេតុការជូនអតិថិជន និងសាធារណៈជន។
- តាមរយៈទូរស័ព្ទក៏ដូចគ្នាដែរ ភ្នាក់ងារជាប់ពាក់ព័ន្ធអាចហៅទូរស័ព្ទទៅកាន់អតិថិជន ផ្ទាល់ដើម្បីរឹតចំណងទំនាក់ទំនង និងការផ្សព្វផ្សាយនូវផលិតផលថ្មីជូនអតិថិជន។
- តាមប្រព័ន្ធអ៊ីម៉ែល ភ្នាក់ងារដែលពាក់ព័ន្ធដូចជាមន្ត្រីថែរក្សាអតិថិជន ត្រូវបានឆ្លើយតបទៅវិញទៅមកជាមួយអតិថិជន និងផ្សព្វផ្សាយនូវផលិតផលថ្មីៗបន្ថែមឲ្យអតិថិជនទាំងចាស់ទាំងថ្មីបានដឹង។

## ៣.៤ យុទ្ធសាស្ត្រលើកត្តាមនុស្សសាស្ត្រ

ដោយសារតែ ធនាគារ បម្រើនូវផលិតផលសេវាកម្ម ហេតុនេះកត្តាមនុស្សសាស្ត្រ ពិតជាមានសារៈសំខាន់ណាស់ចំពោះ ធនាគារ កាណាឌីយ៉ា កអ។ ធនាគារមានយុទ្ធសាស្ត្រលើកត្តាមនុស្សសាស្ត្រដូចខាងក្រោម៖

**វប្បធម៌ការងារ របស់ធនាគារ កាណាឌីយ៉ ក.អ**

- មានការតាំងចិត្ត ប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងការសម្រេចស្នាដៃ និងព្យាយាមធ្វើការឲ្យមានប្រសិទ្ធិភាព។
- សុភាពរាបសា ទន់ភ្លន់ តែម៉ឺងមាត់ចំពោះការងារ។
- ប្រឹងប្រែងរៀនសូត្ររៀនសូត្រពីខ្លួនឯង រៀនសូត្រពីអ្នកដទៃ និងអ្វីៗដែលនៅជុំវិញខ្លួនដោយយកចិត្តទុកដាក់ ប្រុងប្រយ័ត្ន មិនប្រមាថការងារ មិនធ្វេសប្រហែស។
- ប្រកាន់នូវសីលធម៌ កាយ វាចា ចិត្តល្អប្រសើរ ប្រកបដោយកត្តញ្ញូកតវេទីតា។
- ម្ចាស់ការលើការងារ ប្រកបដោយការទទួលខុសត្រូវខ្ពស់។

- ការឲ្យតម្លៃគ្នា និងផ្តល់នូវការគោរព។
- ស្អាតស្អំ មិនពុករលួយ មិនស៊ីសំណូក។
- ស្មោះត្រង់ មានសាមគ្គីភាព ឯកភាព។
- ការញញឹមរាក់ទាក់។

**ភ្នាក់ងារលក់ផ្ទាល់**

- ការងាររបស់ភ្នាក់ងារលក់ មិនមែនតផ្សព្វផ្សាយនោះទេគឺជំរុញឲ្យអតិថិជនប្រើប្រាស់សេវាកម្ម បញ្ញើ-សន្សំ ព្រមទាំងរក្សាការសម្ងាត់របស់អតិថិជន។ រក្សាទំនាក់ទំនងល្អជាមួយអតិថិជន និងរូបភាពវិជ្ជមានរបស់ធនាគារចំពោះអតិថិជន។
- ធ្វើការទំនាក់ទំនងដោយ ការចុះទៅជួបផ្ទាល់ ឬ តាមទូរស័ព្ទ ដើម្បីទំនាក់ទំនងល្អជាមួយអតិថិជន។
- រាល់ពេលចុះផ្សព្វផ្សាយបុគ្គលិកលក់ ត្រូវស្លៀកពាក់ឯកសណ្ឋាន មានកាតបុគ្គលិធនាគារជាការសម្គាល់។
- សិក្សាស៊ីជម្រៅច្បាស់លាស់នូវរាល់ព័ត៌មាន នីតិវិធីនៃការប្រើប្រាស់ អត្ថប្រយោជន៍។

**ភ្នាក់ងារបម្រើអតិថិជន**

- ផ្តល់ព័ត៌មាន ពន្យល់ និងណែនាំ ផ្តល់យោបល់ពីសេវាបញ្ញើ-សន្សំជូនអតិថិជន។
- រីករាយទទួលស្វាគមន៍ និងជំរាបសួរចំពោះការអញ្ជើញមកកាន់ធនាគារ។
- ឆ្លើយនឹងសំណួរ និងដោះស្រាយរបស់អតិថិជនដែលបានលើកឡើង។
- រក្សាភាពថ្លៃថ្នូរ សំដីគួរសមរួសរាយរាក់ទាក់ អត់ធ្មត់នឹងអតិថិជនដើម្បីរក្សាទំនាក់ទំនងល្អ។
- ប្រើពាក្យសំដី និងអកប្បកិរិយារាក់ទាក់ ដើម្បីសួរពីតម្រូវការអតិថិជន។
- បុគ្គលិកត្រូវចេះឆ្លៀតពេលណែនាំពីសេវាផ្សេងទៀតដូចជា ការប្រើប្រាស់ប័ណ្ណអេធីអិមកំ ដូចជាសេវាដទៃទៀតរបស់សេវាបញ្ញើ-សន្សំ។

## ៣.៥. យុទ្ធសាស្ត្រលើកត្តារូបសាស្ត្រ

យុទ្ធសាស្ត្រលើកត្តារូបសាស្ត្រ គឺជាយុទ្ធសាស្ត្រមួយផ្សេងទៀតដែល ធនាគារ កាណាឌីយ៉ា ក.អ ធ្វើឡើងដើម្បីបំពេញចិត្តដល់អតិថិជនក្នុងការប្រើប្រាស់សេវាកម្មរបស់ខ្លួន។ ធនាគារ កាណា ឌីយ៉ា ក.អ បានរៀបចំកែលម្អទៅលើការិយាល័យ គ្រឿងបរិក្ខា និងសម្ភារៈផ្សេងៗដែលចូលរួមក្នុងការផ្តល់ សេវាកម្មដើម្បីទាក់ទាញ និងផ្តល់ភាពងាយស្រួលក្នុងការបម្រើអតិថិជន។ ចំពោះ ធនាគារ កាណាឌីយ៉ា ក.អ ទីស្នាក់ការកណ្តាល

គឺបានរៀបចំនូវកត្តារូបសាស្ត្រ ដែលមានលក្ខណៈដូចខាងក្រោមៈ

**រូបសាស្ត្រខាងក្នុងនៃកន្លែងផ្តល់សេវាកម្ម**

- រូប រឺនិមិត្តសញ្ញារបស់ធនាគារ រូបរង្វង់មូលបានកែច្នៃ ជារង្វង់មានលក្ខណៈស្រដៀង នឹងកាក់មាស នឹងអមដោយឈ្មោះរបស់ធនាគារ កាណាឌីយ៉ា កអ ជាអក្សរខ្មែរ ចិន និងអង់គ្លេសនៅខាងឆ្វេង។ និមិត្តសញ្ញានេះ គឺធ្វើឲ្យអតិថិជនងាយចំណាំ និងស្គាល់ច្បាស់ពីធនាគារ។
- ការរចនាផ្នែកខាងក្នុង នៅក្នុងកន្លែងផ្តល់សេវាកម្ម គឺមានទីធ្លាធំទូលាយដែលអាចឲ្យអតិថិជនងាយស្រួលក្នុងការអង្គុយរងចាំការផ្តល់សេវាពីភ្នាក់ងារប្រកបដោយផាសុខភាព។
- ឧបករណ៍ផ្តល់សេវាកម្ម សម្រាប់ឧបករណ៍ផ្តល់សេវាកម្ម គឺធនាគារ បានបំពាក់នូវ ម៉ាស៊ីនអេឡិចត្រូនិចដូចជា កុំព្យូទ័រ ម៉ាស៊ីនឆូតកាត និងឧបករណ៍ផ្សេងៗទៀត ដែលធ្វើ ឲ្យការប្រតិបត្តិការ ការផ្តល់សេវាកម្មមានភាពរហ័សទាន់ចិត្ត។
- បរិយាកាស គឺសំដៅលើបុគ្គលិក ឬភ្នាក់ងារបម្រើសេវាអតិថិជនទាំងអស់ នៅក្នុងធនាគារ។ ក្នុងនោះ បុគ្គលិកនីមួយៗសុទ្ធតែជាមនុស្ស ដែលមានភាពរួសរាយរាក់ទាក់ និងបង្ហាញស្នាមញញឹមជានិច្ច ដែលផ្តល់ភាពកក់ក្តៅជូនអតិថិជន។
- ខ្យល់អាកាស ក្នុងអគារទាំងមូល ជាពិសេសកន្លែងបម្រើសេវាអតិថិជន គឺមានរៀបចំបំពាក់នូវម៉ាស៊ីនត្រជាក់ដែលប្រកបដោយផាសុខភាព ធ្វើឲ្យអតិថិជនងាយស្រួល និងមិនធុញទ្រាន់ក្នុងការអង្គុយរងចាំ។

**រូបសាស្ត្រខាងក្រៅនៃកន្លែងផ្តល់សេវាកម្ម**

- ការរចនាផ្នែកខាងក្រៅ ចំពោះការរចនាម៉ូតអគារខាងក្រៅ... គឺមានការទាក់ទាញណាស់ ដោយសារតែទីធ្លា និងអាគាររបស់ធនាគារ កាណាឌីយ៉ាក.អ ទីស្នាក់ការកណ្តាលមានលក្ខណៈធំទូលាយ។ ចំណែកឯស្លាកឈ្មោះ និងរូបសញ្ញារបស់ធនាគារ គឺធ្វើឡើងទៅតាមស្តង់ដារ ដែលធ្វើឲ្យអតិថិជនស្រួលមើលច្បាស់ និងងាយចំណាំ។
- កន្លែងចំណត ដើម្បីបង្កលក្ខណៈងាយស្រួលក្នុងការចេញចូលរបស់អតិថិជន ធនាគារបាន រៀបចំចំណតដែលមានលក្ខណៈសមរម្យសម្រាប់តែអតិថិជន ។

**កត្តារូបសាស្ត្រផ្សេងទៀត**

- ឯកសណ្ឋាន ចំពោះឯកសណ្ឋានបុគ្គលិក គឺមានភាពសម្បរម្យ និងមានកាតឈ្មោះរាល់ពេល ចូលក្នុងបរិវេណធនាគារ។

- ខិតប័ណ្ណ គឺបានបោះផ្សព្វផ្សាយទៅតាមផលិតផលសេវាកម្មនីមួយៗ ដែលបញ្ជាក់ពីអត្ថន័យលក្ខខ័ណ្ឌ ច្បាស់លាស់ ហើយអាចធ្វើឲ្យអតិថិជនងាយយល់។
- គេហទំព័រ គឺបានរៀបចំយ៉ាងពិសេសសំរាប់អតិថិជនដែលត្រូវការព័ត៌មានលំអិតពីធគារ។ ការប្រើប្រាស់គេហទំព័រយើងអាចមើលវាបានបីភាសាគឺភាសាខ្មែរ ភាសាអង់គ្លេសនិងភាសាចិន។

## ៣.៦. យុទ្ធសាស្ត្រផលិតភាព និងគុណភាព

យើងឃើញថា ធនាគារកាណាឌីយ៉ា ក.អ ទីស្នាក់ការកណ្តាលគឺជាធនាគារមួយ ដែលមានការទទួលស្គាល់ពីសំណាក់អតិថិជន តាមរយៈការប្រើប្រាស់ផលិតផលសេវាកម្មប្រកបទៅដោយផលិតភាព និងគុណភាព។ ធនាគារ កាណាឌីយ៉ាក.អ បានបញ្ជាក់ពីផលិតភាព និងគុណភាពតាមរយៈដូចខាងក្រោម៖

- ធនាគារមានអាយុកាលវ័យចំណាស់ និងមានកេរ្តិ៍ឈ្មោះល្បីល្បាញ។
- ធនាគារមានផលិតផលសេវាកម្មច្រើនហើយអតិថិជននឹងទទួលបានសេចក្តីណែនាំ និងច្នេកទេសក្នុងការប្រើប្រាស់។
- ធនាគារ មានសាខាជាច្រើនទូទាំងប្រទេស ហើយការរចនាម៉ូតអគារ មានលក្ខណៈប្រណិតធំទូលាយ។
- ធនាគារមានដើមទុនតម្កល់ច្រើននៅធនាគារជាតិ ហើយជាធនាគារមួយដែលមានការទទួលស្គាល់ និងទទួលបានអាជ្ញាប័ណ្ណត្រឹមត្រូវ។
- ធនាគារ បានបំពាក់នូវគ្រឿងសក្ការៈ ឧបករណ៍ប្រើប្រាស់ ដែលមានលក្ខណៈទំនើបៗក្នុង ការបម្រើសេវាកម្មជូនអតិថិជនដូចជាម៉ាស៊ីនកុំព្យូទ័រ ម៉ាស៊ីនឆូតកាត ម៉ាស៊ីនអេធីអិម-ល-
- ការផ្តល់សេវាកម្មជូនអតិថិជន មានភាពលឿនរហ័សទាន់ចិត្ត និងជួយដោះស្រាយបញ្ហាផ្សេងៗជូនអតិថិជន។
- បុគ្គលិកមានចំណេះដឹង ជំនាញ សមត្ថភាពខ្ពស់ក្នុងការធ្វើការងារប្រកបដោយក្រមសីលធម៌។

# ជំពូកទី៤

# ការវិភាគSWOT

បន្ទាប់ពីការសិក្សាលើផ្នែកសំខាន់ៗជាច្រើនរបស់ធនាគារកាណាឌីយ៉ា ក.អ ការស្រាវជ្រាវបានរកឃើញថា ធនាគារនេះមាន ៖

## ៤.១. ចំណុចខ្លាំង

តាមរយៈការស្រាវជ្រាវនិងការវិភាគលើទៅការស្ទង់មតិអតិថិជនបានឲ្យដឹងថាធនាគារកាណាឌីយ៉ាក.អ មានចំណុចវិជ្ជមានមួយចំនួនដូចខាងក្រោម៖

- តាមរយៈនៃការស្ទង់មតិរបស់អតិថិជនបានឲ្យដឹងថា អតិថិជនស្ទើរតែទាំងអស់យល់ឃើញថាការបើកគណនីនៅធនាគារ កាណាឌីយ៉ា ក.អ ទីស្នាក់ការកណ្តាលមានភាពងាយស្រួល។
- តាមលទ្ធផលដែលបានមកពីការស្ទង់មតិ អតិថិជនបានឲ្យដឹងថាអតិថិជនភាគច្រើនពេញចិត្តនូវអត្រាការប្រាក់។
- យោងតាមការវិភាគទិន្នន័យ បានបង្ហាញឲ្យយើងឃើញថា អតិថិជនលើសពី២/៣ និយាយថាអត្រាការប្រាក់បញ្ញើ ស្មើ ឬច្រើនជាង បើធៀបជាមួយនឹងធនាគារដទៃ។
- តាមលទ្ធផលដែលបានមកពីការស្ទង់មតិ អតិថិជនបានឲ្យដឹងថា អតិថិជនភាគច្រើនពេញចិត្តនឹង គុណភាព និងសេវាកម្មរបស់ធនាគារ។
- តាមរយៈការវិភាគទិន្នន័យបានឲ្យដឹងថា អតិថិជនប្រហែល ២/៣ ពេញចិត្តនឹង សុជីវធម៌សីលធម៌របស់បុគ្គលិកធនាគារ កាណាឌីយ៉ា ក.អ ទីស្នាក់ការកណ្តាល។
- តាមការស្ទង់មតិអតិថិជនសង្កេតឃើញថាបុគ្គលិកនៅធនាគារ កាណាឌីយ៉ា ក.អ ទីស្នាក់ការកណ្តាលភាពរួសរាយរាក់ទាក់ចំពោះការបម្រើសេវាកម្មអតិថិជន ព្រមទាំងផ្តល់នូវសេចក្តីពេញចិត្តទៅអតិថិជន តាមរយៈការផ្តល់សេវាកម្ម និងការទទួលស្វាគមន៍អតិថិជន។
- តាមការវិភាគ បានបង្ហាញថាអតិថិជនមួយចំនួនធំ មានភាពពេញចិត្តទៅលើការយកចិត្តទុកដាក់របស់បុគ្គលិកនៅពេលបម្រើសេវាកម្មជូនទៅអតិថិជន និងបំពេញទៅតាមតម្រូវរបស់ពួកគាត់។
- តាមការវិភាគទៅលើកម្រិតនៃការពេញចិត្តរបស់អតិថិជន បង្ហាញថាអតិថិជនភាគច្រើនបំផុតមានការពេញចិត្តទៅលើការបំពាក់នូវម៉ាស៊ីនស្វ័យប្រវត្តិ ដើម្បីជាភាពងាយស្រួលក្នុងការដំណើរប្រតិបត្តិការផ្នែកបម្រើសេវាកម្មអតិថិជនរបស់ធនាគារផងដែរ។

- តាមរយៈការអង្កេតជាក់ស្តែង ធនាគារមានបំពាក់នូវម៉ាស៊ីនចម្រុះទឹកក្តៅនិងត្រជាក់ ទូរទស្សន៍ ម៉ាស៊ីនត្រជាក់ បន្ទប់វីអាយភីសំរាប់ពិគ្រោះយោបល់ជាមួយអតិថិជន បំពាក់នូវ ជណ្តើរយន្ត សម្រាប់សំរួលដល់ការធ្វើដំណើរឡើងចុះរបស់អតិថិជនដែលបំពេញនូវសេចក្តីពេញចិត្តទៅដល់អតិថិជន។

### ៤.២. ចំណុចខ្សោយ

- តាមរយៈការវិភាគទិន្នន័យ នៃការស្ទង់មតិអតិថិជន បានឲ្យដឹងថាអតិថិជនភាគច្រើនស្គាល់ផលិតផលបញ្ញើ-សន្សំ តាមរយៈគ្រួសារ និងមិត្តភក្តិ ហើយអតិថិជនភាគតិចតែប៉ុណ្ណោះដែលស្គាល់ផលិតផលនេះតាមរយៈមធ្យោបាយផ្សព្វផ្សាយរបស់ធនាគារ។
- តាមទិន្នន័យនៃការសាកសួរទៅកាន់អតិថិជន មានអតិថិជនមួយចំនួនតូចមានការត្អូញត្អែរថាអត្រាការប្រាក់ដែលទទួលបានពីផ្នែកឥណទានមានកម្រិតខ្ពស់ រីឯអត្រាការប្រាក់បញ្ញើមានកម្រិតទាប។

### ៤.៣. ឱកាស

- ធនាគារកាណាឌីយ៉ាមានប្រតិបត្តិការ២៥រាជធានីក្រុងទូទាំងព្រះរាជាណាចក្រកម្ពុជាដែលធ្វើឲ្យធនាគារកាណាឌីយ៉ាកាន់តែមានឱកាសច្រើនក្នុងការទាក់ទាញអតិថិជនមកប្រើប្រាស់សេវាប្រាក់បញ្ញើរសន្សំក៏ដូចជាទាក់ទាញអតិថិជនមកប្រើប្រាស់សេវាផ្សេងៗ។
- ទទួលទំនុកចិត្តពីអតិថិជនដោយសារតែធនាគារកាណាឌីយ៉ាមានកេរ្តិ៍ឈ្មោះដែលធ្វើអោយធនាគារទទួលបានប្រាក់បញ្ញើសន្សំពីមួយឆ្នាំទៅមួយឆ្នាំមានការកើនឡើង។
- ធនាគារកាណាឌីយ៉ាមានផលិតផលសំបូរបែបដែលជាហេតុធ្វើឲ្យអតិថិជនមានជម្រើសច្រើនក្នុងការប្រើប្រាស់ផលិតផលដែលសាកសមនឹងតម្រូវការរបស់ខ្លួន។
- សេវារហ័សទាន់ចិត្តដោយមិនចាំបាច់ឲ្យអតិថិជនចំណាយពេលរងចាំយូរមកដាក់ប្រាក់បញ្ញើក៏ដូចជាផលិតផលផ្សេងទៀត។

### ៤.៤. ការគំរាមគំហែង

ក្រៅពីចំណុចមានឱកាសហើយធនាគារកាណឌីយ៉ា ក៏ប្រឈមនឹងការគំរាមគំហែងដែលបណ្តាលមកពីកត្តាផ្សេងៗដូចជាៈ

- ការកើតឡើងនៅធនាគារក៏ដូចជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដែលធ្វើឲ្យធនាគារកាណាឌីយ៉ាមានដៃគូរប្រកួតប្រជែងកាន់តែច្រើន
- ការប្រកួតប្រជែងលើអត្រាការប្រាក់។

# សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

## ១. សេចក្តីសន្និដ្ឋាន

តាមរយៈការស្រាវជ្រាវ ពីកាណាឌីយ៉ា ក.អ ទីស្នាក់ការកណ្តាលរួចមកអាចសន្និដ្ឋានបានថា ធនាគារបានផ្តោតទៅលើគុណភាពសេវាកម្ម ដែលជាប់ពាក់ព័ន្ធនឹង សេចក្តីទុកចិត្តរបស់អតិថិជន ការទទួលខុសត្រូវរបស់បុគ្គលិកនៃធនាគារ ការស្វែងយល់ពីអតិថិជន និងការកំណត់ថ្លៃ (ការប្រាក់) ព្រមទាំងគុណភាពផលិតផលនីមួយៗ ហើយធនាគារបានផ្តល់ភាពងាយស្រួលដល់អតិថិជននូវភាពងាយស្រួលក្នុងការបើកគណនីប្រាក់បញ្ញើ និងការប្រើប្រាស់សេវាកម្មប្រាក់បញ្ញើ រួមមាន ប្រព័ន្ធធនាគារតាមទូរស័ព្ទ (Mobile Banking ឬ Canadia Bank) និងម៉ាស៊ីនដាក់ប្រាក់ (Cash-In)។ ម្យ៉ាងវិញទៀត ធនាគារបានប្រើយុទ្ធសាស្ត្រជាច្រើនដែលរួមមាន យុទ្ធសាស្ត្របង្កើនជំនឿរបស់អតិថិជនមកលើធនាគារ តាមរយៈការបង្កើនកេរ្តិ៍ឈ្មោះធនាគារឲ្យល្បីល្បាញការជ្រើសរើសបុគ្គលិកដែលមានជំនាញ ចំនេះដឹង និងទំនួលខុសត្រូវខ្ពស់ ព្រមទាំងការបង្ហាត់បុគ្គលកទាំងនោះ ដើម្បីបម្រើសេវាកម្មដែលល្អប្រពៃស្របតាមតម្រូវការរបស់អតិថិជន។ មិនតែប៉ុណ្ណោះ ថ្នាក់ដឹកនាំរបស់ធនាគារ ពោរពេញទៅដោយសមត្ថភាព ជំនាញ ចំណេះដឹង និងភាពជាអ្នកដឹកនាំខ្ពស់ដើម្បីតម្រង់ទិសបុគ្គលិក និងដឹកនាំពួកគាត់ទៅ ដល់គោលដៅមួយដែលជួយឲ្យធនាគារមានភាពរីកចម្រើនខ្លាំង។ ក្រៅពីនេះ ធនាគារកាណាឌីយ៉ាបានទទួលពានរង្វាន់ជាច្រើនបន្តបន្ទាប់ក្នុងកំឡុងពេលប៉ុន្មានឆ្នាំជាប់គ្នា។

តាមគោលការណ៍ណែនាំ និងការធ្វើទីផ្សារតាមរយៈសេវាកម្មធនាគារតាមទូរស័ព្ទដៃ ឬអ៊ីមធើណែត (E-Banking) ដើម្បីលើកទឹកចិត្តជូនដល់អតិថិជនបើកគណនីមានកាលកំណត់តាមរយៈសេវាកម្មធនាគារតាមទូរស័ព្ទដៃ ឬអ៊ីនធើណែត និងបង្កើនប្រាក់បញ្ញើឃើញថា នៅឆ្នាំ ២០២១ ធៀបទៅនិងឆ្នាំ ២០២០ ធនាគារបានផ្តល់អត្រាការប្រាក់ពិសេស បន្ថែម ០.១៥ ភាគរយ ក្នុងមួយឆ្នាំលើគណនីមានកាលកំណត់រយៈពេល ១២ខែ និង ០.២៥ ភាគរយ ក្នុងមួយឆ្នាំសម្រាប់គណនីមានកាលកំណត់រយៈពេល ២៤ខែ។ ដូចនេះការលើកទឹកចិត្ត និងផ្តល់អត្ថប្រយោជន៍កាន់តែច្រើនឡើង ជាងឆ្នាំ ២០២០។

## ២. ការផ្តល់អនុសាសន៍

បន្ទាប់ពីធ្វើការស្រាវជ្រាវមកយើងបានថាធនាគារកាណាឌីយ៉ា ក.អ ទីស្នាក់ការកណ្តាលមានចំណុចល្អៗនិងការគាំទ្រយ៉ាងច្រើន ពីសំណាក់អតិថិជន។ទន្ទឹមនិងនេះ ធនាគារក៏មានចំណុចខ្វះខាតមួយចំនួនដែលត្រូវកែលម្អឲ្យកាន់តែប្រសើរឡើង ដូចតទៅ៖

- ធនាគារគួរតែបង្កើនប្រាក់អត្រាការប្រាក់ ចំពោះគណនីបញ្ញើមានកាលកំណត់
- ធនាគារគួរតែបង្កើនប្រភេទសេវានៃ សេវាប្រាក់បញ្ញើ-សន្សំបន្ថែមទៀត

- ធនាគារគួរតែបន្ថែមម៉ាស៊ីនដាក់-ដកប្រាក់ ATM នៅតាមទីសាធារណៈ
- ធនាគារគួរតែបង្កើន QR payment នៅតាមទីតាំងអាជីវកម្មនានា ទូទាំងប្រទេស
- ធនាគារគួរតែពន្លឿនការដោះស្រាយបញ្ហា ដែលអតិថិជនមានដូចជា ការផ្ទេរប្រាក់ខុសគណនី ឬការជាប់ប្រាក់ក្នុងម៉ាស៊ីនដាក់ប្រាក់ ការកាត់សាច់ប្រាក់ចេញពីគណនីប៉ុន្តែមិនទទួលបានក្រដាសប្រាក់ពីម៉ាស៊ីន
- ធនាគារគួរតែអភិវឌ្ឍលើវិស័យប្រព័ន្ធ E-Banking ឲ្យកាន់តែរហ័សទាន់ចិត្ត។

# ឯកសារយោង

## ឯកសារយោងជាភាសាខ្មែរ


១. ធនាគារជាតិនៃកម្ពុជា,(១៩៩៩) “ ច្បាប់ស្ដីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ'ទំព័រទី១

២. សៀវភៅ "រូបិយវត្ថុ និងធនាគារ" សាស្ត្រាចារ្យ ងួន ហេង

៣. សៀវភៅ "រូបិយវត្ថុ និងធនាគារ" សាស្ត្រាចារ្យ សួន ចំរើន, ឆ្នាំ ២០១៦-២០១៧

៤. សៀវភៅ "គណិតវិទ្យាសេដ្ឋកិច្ច" សម្រាប់ថ្នាក់ឆ្នាំមូលដ្ឋាន,សាស្ត្រាចារ្យ "ជា សែម",ឆ្នាំ ២០១៦-២០១៧

៥. សៀវភៅរបាយការណ៍ប្រចាំ ២០១៨ របស់ធនាគារកាឌីយ៉ា

៦. សៀវភៅរបាយការណ៍ប្រចាំ ២០២០ របស់ធនាគារកាណាឌីយ៉ា


## ឯកសារយោងជាភាសាបរទេស


៧. https://knoema.com/atlas/Cambodia/GDP?mode=amp , Cambodia GDP 2010-2019

៨. https://en.m.wikipedia.org/wiki/List_of_banks_in_Cambodia


## ឯកសារដកស្រង់ចេញពីគេហទំព័រ


៩. www.canadiabank.com.kh

## ឧបសម្ព័ន្ធទី១

## កម្រងសំណួរស្រាវជ្រាវស្ដីអំពី " ប្រាក់បញ្ញើ-សន្សំរបស់ធនាគារ កាណាឌីយ៉ា ក.អ ទីស្នាក់ការកណ្ដាល˝

យើងខ្ញុំជានិស្សិតនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ផ្នែកវិទ្យាសាស្រ្តសេដ្ឋកិច្ច ជំនាញធនាគារនិងហិរញ្ញវត្ថុ ឆ្នាំទី៤ ជំនាន់ទី១៤។ ខ្ញុំកំពុងធ្វើនិក្ខេបបញ្ចប់ការសិក្សា ក្រោមប្រធានបទ "សេវាប្រាក់ បញ្ញើ-សន្សំរបស់ធនាគារ កាណាឌីយ៉ា ក.អ.ទីស្នាក់ការកណ្ដាល˝។ អាស្រ័យហេតុនេះខ្ញុំសូមសំនូមពរដល់អតិថិជនទាំងអស់ដែលកំពុងបានប្រើប្រាស់ផលិតផល និងសេវាកម្មរបស់ ធនាគារកាណាឌីយ៉ា ក.អ ទីស្នាក់ការកណ្ដាលមេត្តាជួយចំណាយពេលវេលាក្នុងការឆ្លើយ និងផ្ដល់នូវព័ត៌មានមួយចំនួនដល់យើងខ្ញុំតាមរយៈកម្រងសំនួរខាងក្រោមដោយក្ដីអនុគ្រោះ។

I. **ព័ត៌មានផ្ទាល់ខ្លួន**

១. ភេទ៖ ☐ ស្រី ☐ ប្រុស

២. អាយុ៖ ☐ ១៨ឆ្នាំ ដល់ ២៥ឆ្នាំ ☐ ៣៦ឆ្នាំ ដល់ ៦០ឆ្នាំ

៣. មុខរបរ៖ ……………………………………………………..

II. **ផលិតផល និងសេវាកម្មរបស់ធនាគារ កាណាឌីយ៉ា ក.អ**

១. តើប្រភេទផលិតផល និ ងសេវាកម្មណាមួយដែលអ្នកប្រើប្រាស់កាណាឌីយ៉ា កអ ទីស្នាក់ការកណ្ដាល?

☐ គណនីចរន្ត ☐ គណនីកុមារ

☐ គណនីសន្សំ ☐ គណនី Elite

☐ គណនីបញ្ញើមានកាលកំណត់ ☐ ឥណទាន

☐ ផ្សេងៗ (សូមបញ្ជាក់)……………………………………..

២. តើអ្នកប្រើប្រាស់ផលិតផល ឬសេវាកម្មខាងលើអស់រយៈពេលប៉ុន្មាន?

☐ ៣ខែ ☐ ៦ខែ ☐ ៩ ខែ

☐ ១ឆ្នាំ ☐ លើសពីមួយឆ្នាំ

៣. តើអ្នកស្គាល់នូវផលិតផលប្រាក់បញ្ញើ-សន្សំតាមរបៀបណា?

☐ គ្រួសារ ☐ មិត្តភក្តិ ☐ ប្រព័ន្ធអ៊ីនធឺណេត

☐ ទូរទស្សន៍ ☐ កាសែត& ទស្សនាវដ្ដី

៤. ចំពោះការបើកគណនី តើមានលក្ខណៈដូចម្ដេច?

☐ ងាយស្រួល ☐ ងាយស្រួលខ្លាំង ☐ ងាយស្រួលខ្លាំងណាស់

☐ ស្មុគស្មាញ ☐ ស្មុគស្មាញខ្លាំងណាស់

៥. តើអ្នកពេញចិត្តនូវអត្រាការប្រាក់ដែលធនាគារផ្ដល់ជូនចំពោះគណនីបញ្ញើ-សន្សំដែរឬទេ?

☐ ពេញចិត្តខ្លាំងណាស់ ☐ មិនពេញចិត្ត

☐ ពេញចិត្តខ្លាំង ☐ មិនពេញចិត្តសោះ

៦. បើប្រៀបធៀបទៅនឹងធនាគារដទៃទៀត តើអត្រាការប្រាក់ដែលធនាគារកាណាឌីយ៉ា ក.អ ផ្ដល់ជូនលោកអ្នកលើផ្នែកប្រាក់បញ្ញើ-សន្សំមានកំរិតដូចម្ដេច?

☐ ខ្ពស់ជាង ☐ ស្មើគ្នា ☐ ទាបជាង

៧. តើអ្នកយល់យ៉ាងណាចំពោះការដាក់តំកល់លុយ 10$ ចំពោះការបើកគណនីថ្មី?

☐ ច្រើនណាស់ ☐ ច្រើន

☐ មធ្យម ☐ តិច

☐ តិចណាស់

៨. តើកត្តាចំបងអ្វីដែលជំរុញឲ្យអ្នកមកដាក់ប្រាក់សន្សំនៅធនាគារ កាណាឌីយ៉ ក.អ ទីស្នាក់ការ កណ្ដាល?

☐ ទំនុកចិត្ត ☐ សុវត្ថិភាព

☐ សេវាកម្ម ☐ អត្រាការប្រាក់

៩. តើអ្នកពេញចិត្តនឹងគុណភាពនៃផលិតផល និងសេវាកម្មដែលផ្តល់ជូនអតិថិជនរបស់ធនាគារកាណាឌីយ៉ា ក.អ ទីស្នាក់ការកណ្តាលកំរិតណា?

☐ ពេញចិត្តខ្លាំងណាស់ ☐ ពេញចិត្តខ្លាំង

☐ ពេញចិត្ត ☐ មិនពេញចិត្ត

☐ មិនពេញចិត្តសោះ

១០. តើអ្នកមានបំណងចង់ប្រើប្រាស់នូវសេវាកម្មផលិតផលប្រាក់បញ្ញើ-សន្សំ ដែលអ្នកមិនទាន់ប្រើប្រាស់ឬទេ?

☐ ចង់ប្រើប្រាស់ខ្លាំង ☐ មិនចង់ប្រើប្រាស់

☐ ចង់ប្រើប្រាស់ខ្លាំង ☐ ចង់ប្រើប្រាស់

☐ មិនចង់ប្រើប្រាស់ទាល់តែសោះ

១១, តើបុគ្គលិកធនាគារមានសុជីវធម៌-សុជីវធម៌ ចំពោះអតិថិជនកំរិតណា?

☐ កំរិតខ្ពស់ណាស់ ☐ កំរិតខ្ពស់

☐ កំរិតមធ្យម ☐ កំរិតទាប

☐ កំរិតទាបណាស់

## ឧបសម្ព័ន្ធទី២

## កម្រងសំណួរស្រាវជ្រាវ

កម្រងសំណួរនេះទាក់ទងនឹងការស្រាវជ្រាវ និងចុះកម្មសិក្សានៅ ធនាគារ កាណាឌីយ៉ា ក.អ ទីស្នាក់ការកណ្តាល ដែលមានប្រធានបទស្តីអំពី "សេវាប្រាក់បញ្ញើ-សន្សំរបស់ធនាគារកាណាឌីយ៉ា ក.អ ទីស្នាក់ការកណ្តាល ដែលធ្វើឡើងដោយ និស្សិតឈ្មោះ ស៊ុត គន្ធា ឆ្នាំទី៤ ជំនាន់ទី១៤ ផ្នែក ធនាគារនិងហិរញ្ញវត្ថុនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

១. តើធនាគារ កាណាឌីយ៉ា ក.អ មានប្រវត្តិកកើតយ៉ាងដូចម្តេច?

២. តើធនាគារមានចក្ខុវិស័យ បេសកកម្ម និងគោលដៅអ្វីខ្លះ?

៣. តើរូបសញ្ញា មានអត្ថន័យបែបណា?

៤. តើធនាគារមានសាខាចំនួនប៉ុន្មាន?

៥. តើផលិតផលនិងសេវាកម្មរបស់ ធនាគារ កាណាឌីយ៉ា ក.អ មានអ្វីខ្លះ?

៦. តើធនាគារ កាណាឌីយ៉ា ក.អ បានផ្តល់អត្រាការប្រាក់ទៅតាមប្រភេទប្រាក់បញ្ញើនីមួយៗយ៉ាងដូចម្តេចដែរ?

៧. តើអតិថិជនត្រូវធ្វើដូចម្តេចដើម្បីបើកគណនីបញ្ញើនីមួយៗរបស់ធនាគារ?

៨. តើអតិថិជនត្រូវធ្វើដូចម្តេចដើម្បីបិទគណនីបញ្ញើនីមួយៗរបស់ធនាគារ?

៩. តើអត្ថប្រយោជន៍អ្វីខ្លះដែលសេវាប្រាក់បញ្ញើបានផ្តល់ឲ្យអតិថិជននិងធនាគារ?

១០. តើធនាគារមានយុទ្ធសាស្ត្របែបណាខ្លះដើម្បីរក្សាអតិថិជនក្នុងការយកប្រាក់មកផ្ញើ?

១១. តើធនាគារការប្រើប្រាស់យុទ្ធសាស្ត្រផ្សព្វផ្សាយយ៉ាងដូចម្តេចខ្លះ?